18K-CA081-柬埔寨文：萬世明燈-字.pdf 1 2019/8/1 下午 02:08:55

# អត្ថប្រទីប

## សម្តែងអំពី

## ប្រយោជន៍បីយ៉ាង

ម. ឧត្តមប្រីជា ចាប-ពិន
ក្រុមជំនុំព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ
នៅព្រះរាជបណ្ណាល័យ កម្ពុជា
ក្រុងភ្នំពេញ
រៀបរៀងដោយ

គណៈរដ្ឋមន្ត្រី និងព្រះសង្ឃនាយក ទាំងពីរគណៈ
អនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ
បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៦៣ គ.ស. ២០១៩

CA081
អត្ថប្រទីប
Atthapadīpa

As this is a Dhamma text,
we request that it be treated with respect.
If you are finished with it,
please pass it on to others or
offer it to a monastery, school or public library.
Thanks for your co-operation.
**Namo Amitabha!**

《柬埔寨文：萬世明燈 Atthapadīpa》
財團法人佛陀教育基金會 印贈
Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F, 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Website: www.budaedu.org ; overseas@budaedu.org,
**This book is for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
CA081

# អត្ថប្បទីប

## សម្តែងអំពី

## ប្រយោជន៍បីយ៉ាង

ម. ខុត្តមប្រីជា ចាប-ពិន

ក្រុមជំនុំព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ

នៅព្រះរាជបណ្ណាល័យ កម្ពុជា

ក្រុងភ្នំពេញ

រៀបរៀងដោយ

គណៈរដ្ឋមន្ត្រី និងព្រះសង្ឃនាយក ទាំងពីរគណៈ

អនុញ្ញាតហើយ

**បោះពុម្ពចែកជាធម្មទាន**

**ព.ស. ២៥៦៣** **គ.ស. ២០១៩**

# ពាក្យប្រារព្ធ

ធម្មកថា “អត្ថប្រទីប” នេះ

ខ្ញុំរៀបរៀងតាមគម្ពីរទាំងឡាយ មានគម្ពីរអង្គុត្តរនិកាយជាដើម ដោយពុទ្ធបរិស័ទទាំងឡាយ ជាបណ្ឌិតខ្លះ គ្រហស្ថខ្លះ មានព្រះតេជព្រះគុណព្រះនាម មាន់ ចៅអធិការវត្តព្រៃរំដេង ឃុំបារាយណ៍ ស្រុកព្រៃឈរ ខេត្តកំពង់ចាម និងឧបាសក ម៉ុម ឧបាសិកាហ៊ុន នៅភូមិព្រៃរំដេង ឃុំ-ស្រុក-ខេត្ត ជាមួយគ្នាជាដើម មករកឲ្យរៀបរៀង បោះពុម្ពផ្សាយជាធម្មបណ្ណាការ ។

១៥
ភ្នំពេញនៅថ្ងៃ ៗ ៣ ឆ្នាំម្សាញ់ត្រីស័ក ព.ស.២៤៨៤

ម. ឧត្តមប្រីជា ចាប-ពិន

# បញ្ជីមាតិកា

មាតិកា ទំព័រ

ប្រយោជន៍បីយ៉ាង..........១
អធិប្បាយពាក្យថាប្រយោជន៍..........១
សម្តែងប្រយោជន៍បីយ៉ាងដោយសង្ខេប..........២

## ទិដ្ឋធម្មិកត្ថប្រយោជន៍

អធិប្បាយប្រយោជន៍ទាន់ភ្នែក..........៤
សម្បទា ៤ យ៉ាង..........៤
កំណាប់ទ្រព្យ ៤ យ៉ាង..........៦
អធិប្បាយឧដ្ឋានសម្បទា..........៨
រឿងបុរសឧបដ្ឋាកកុល្លកសេដ្ឋី..........១០
អង្គរបស់អ្នកជំនួញ ៣ យ៉ាង..........១១
អធិប្បាយអារក្ខសម្បទា..........១៨
វិធីរក្សាទ្រព្យ ៤ យ៉ាង..........១៩
រឿងអបុត្តកសេដ្ឋី..........២២
អធិប្បាយកល្យាណមិត្តតា..........២៥
រឿងសេដ្ឋីបុត្រម្នាក់..........២៦
អធិប្បាយសមជីវិតា..........២៨
ការបាយទ្រព្យ ៤ យ៉ាង..........៣១
បាយទ្រព្យភាគ ១ ដោះបំណុលចាស់..........៣១
បាយទ្រព្យភាគ ១ បុលយកបំណុលថ្មី..........៣៣
យកទ្រព្យភាគ ១ ទៅបោះក្នុងជ្រោះជ្រៅ..........៣៤
យកទ្រព្យភាគ ១ ទៅកប់ទុកជាកំណាប់ព្រេង..........៣៥
រឿងបុរសកំសត់ម្នាក់..........៣៧

# មាតិកា

ទំព័រ

## សម្បរាយិកត្ថប្រយោជន៍


អធិប្បាយប្រយោជន៍ជួនទៅខាងមុខ ........................................ ៤១
សម្បទា ៤ យ៉ាង ........................................ ៤១
អធិប្បាយសទ្ធាសម្បទា ........................................ ៤១
សទ្ធា ៤ យ៉ាង ........................................ ៤២
រឿងសុភមាណព ........................................ ៤៥
សទ្ធា ២ យ៉ាង ........................................ ៤៩
លក្ខណៈបុគ្គលមានសទ្ធា ៣ យ៉ាង ........................................ ៥០
អធិប្បាយសីលសម្បទា ........................................ ៥៣
អធិប្បាយចាគសម្បទា ........................................ ៥៦
ចាគៈ ២ យ៉ាង ........................................ ៥៦
អធិប្បាយសុខតូចនិងសុខធំ ........................................ ៥៨
ឧបាយលះសុខតូចដូរយកសុខធំ ........................................ ៥៩
អធិប្បាយបញ្ញាសម្បទា ........................................ ៦៥


## បរមត្ថប្រយោជន៍


អធិប្បាយប្រយោជន៍ប្រសើរបំផុត ........................................ ៧០
រឿងព្រះធម្មារាមត្ថេរ ........................................ ៧១
បារមីធម៌១០ ........................................ ៧៤
ការចម្លងយកឧបនិស្ស័យ ........................................ ៧៥
និគមវចនៈ ........................................ ៧៦
ពាក្យតាំងសេចក្ដីប្រាថ្នាក្នុងវេលាធ្វើបុណ្យ ........................................ ៧៩

# ពាក្យតាំងសេចក្តីប្រាថ្នា

## ក្នុងវេលាធ្វើបុណ្យទាន

## ផ្សេងៗ

**សុទិន្នំ វត មេ ទានំ អាសវក្ខយាវហំ ហោតុ ។** ទានដែលខ្ញុំបានថ្វាយហើយដោយប្រពៃ, សូមជាបច្ច័យនាំមកនូវកិរិយាអស់ទៅនៃអាសវៈ(ទាំងពួង) ។

# អត្ថប្រទីប

# សម្តែងអំពី

# ប្រយោជន៍បីយ៉ាង

**១- ទិដ្ឋធម្មិកត្ថៈ** ប្រយោជន៍ទាន់ភ្នែក

**២- សម្បរាយិកត្ថៈ** ប្រយោជន៍ជូនទៅខាងមុខ

**៣- បរមត្ថៈ** ប្រយោជន៍ប្រសើរបំផុត

អធិប្បាយពាក្យថាប្រយោជន៍

ពាក្យថា “ប្រយោជន៍” ដែលលោកបញ្ញត្តប្រើក្នុងភាសាខ្មែរនេះ ជាពាក្យបេញមកពីភាសាបាលីថា “បយោជនៈ” ភាសាសំស្រ្កឹតថា “ប្រយោជនៈ” ស្គាល់សេចក្តីថា “ផលដែលសមប្រកប” ឬ “ផលដែលគួរប្រាថ្នា” ។

ពាក្យនេះក្នុងភាសាបាលី ហៅផ្លាស់ប្តូរគ្នាប្រើនសព្ទ, ប្ចូនកាលហៅថា “អត្ថៈ” ប្រែថា “ផល” ឬថា “សេចក្តីបម្រើន” ដូចក្នុងពាក្យថា “ទិដ្ឋធម្មិកត្ថៈ សម្បរាយិកត្ថៈ

បរមត្ថៈ” បួនកាលហៅថា “ហិតៈ” ប្រែថា “ប្រយោជន៍” ឬថា “គុណ” ដូចក្នុងពាក្យថា “ទិដ្ឋធម្មិកហិតៈ សម្បរាយិក-ហិតៈ បរមហិតៈ” បួនកាលហៅថា “សុខៈ” ប្រែថា “សេចក្ដីសុខ” ដូចក្នុងពាក្យថា “ទិដ្ឋធម្មិកសុខ សម្បរាយិកសុខ បរមសុខ” ។ រួបសេចក្ដីថា “ផល-ប្រយោជន៍-សេចក្ដីសុខ-សេចក្ដីបម្រើន ដែលប្រព្រឹត្តនៅក្នុងលោកនេះ ពាក្យថា “អត្ថៈ-ហិតៈ-សុខៈ” អម្បាលនេះ គ្រាន់តែផ្សេងគ្នាដោយតួអក្សរ, តែសម្គាល់សេចក្ដីជាមួយគ្នា សំដៅត្រង់ផលប្រយោជន៍ដែលឲ្យសម្រេចសេចក្ដីសុខកាយសុខចិត្តសមប្រកបតាមសេចក្ដីប្រាថ្នា ដូចគ្នា ។

## សម្ដែងប្រយោជន៍បីយ៉ាងដោយសង្ខេប

១- ទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ យសស័ក្តិ ជាដើម ដែលបុគ្គលស្វែងរកបានមកសមប្រកបតាមសេចក្ដីប្រាថ្នា ជាផលឲ្យកើតសេចក្ដីសុខកាយសប្បាយចិត្ត ឃើញច្បាស់ក្នុងបច្ចុប្បន្ន ឬ ក្នុងវេលាដែលមានជីវិតរស់នៅ, លុះស្លាប់ទៅមិន

ឃើញ គឺយកទៅមិនរួច ឬជូនដំណើរទៅក្នុងភពខាងមុខមិនបាន, យ៉ាងនេះហៅថា ទិដ្ឋធម្មិកត្ថៈ ប្រែថា ប្រយោជន៍ទាន់ភ្នែក នឹងហៅថា ប្រយោជន៍ក្នុងឥធលោក ប្រែថា ប្រយោជន៍ក្នុងលោកនេះ ឬប្រយោជន៍ក្នុងបច្ចុប្បន្នក៏បាន ។

២- សេចក្ដីសុខកាយស្រួលចិត្ត ដែលជាផលកើតអំពីសេចក្ដីប្រព្រឹត្តល្អ ជាប់តាមជូនដំណើរទៅក្នុងភពដែលត្រូវកើតទៀត ជាខាងមុខ ៗ តទៅបាន បីដូចស្រមោល អន្ទោលតាមប្រាណ, យ៉ាងនេះហៅថា សម្បរាយិកត្ថៈ ប្រែថា ប្រយោជន៍ជូនទៅខាងមុខ, នឹងហៅថាប្រយោជន៍ក្នុងបរលោក ប្រែថា ប្រយោជន៍ក្នុងលោកខាងមុខ ឬប្រយោជន៍ក្នុងអនាគតក៏បាន ។

៣- បរមសុខ ដែលកើតអំពីការរួចស្រឡះចាកភ្លើងកិលេស គឺ រាគៈ ទោសៈ មោហៈ និងភ្លើងទុក្ខ គឺជាតិជរា ព្យាធិ មរណៈ ជាសុខយ៉ាងស្ងប់ ឥតមានលាយដោយទុក្ខបន្តិចបន្តួចសោះ, យ៉ាងនេះ ហៅថា បរមត្ថៈ ប្រែថា ប្រយោជន៍ប្រសើរបំផុត គឺព្រះនិព្វាន ។

# ទិដ្ឋធម្មិកត្ថប្រយោជន៍

## អធិប្បាយប្រយោជន៍ទាន់ភ្នែក

ធម៌ដែលជាហេតុឲ្យសម្រេចប្រយោជន៍ទាន់ភ្នែកមាន៤យ៉ាងគឺ

**១- ឧដ្ឋានសម្បទា** ការបរិបូណ៌ដោយព្យាយាម

**២- អារក្ខសម្បទា** ការបរិបូណ៌ដោយការរក្សា

**៣- កល្យាណមិត្តតា** ការគប់មិត្តសំឡាញ់ល្អ

**៤ - សមជីវិតា** ការចិញ្ចឹមជីវិតស្មើ

កាលនឹងអធិប្បាយអំពីសម្បទា ៤ យ៉ាង ដែលជាហេតុឲ្យកើតផលប្រយោជន៍ សេចក្តីសុខ សេចក្តីចម្រើនទាន់ភ្នែក, គួរនឹងពោលអំពីទ្រព្យសម្បត្តិជាមុន ។ ទ្រព្យសម្បត្តិជារបស់ដែលមនុស្សក្នុងលោកទាំងមូលតែងចង់បានក្រៃពេក ព្រោះជាវត្ថុឲ្យសម្រេចសេចក្តីសុខកាយសុខចិត្តច្រើនយ៉ាង ។ មនុស្សអ្នកមានទ្រព្យស្តុកស្តម្ភរមែងមានសេចក្តីរីករាយច្រើន ដោយនឹកសង្ឃឹមក្នុងចិត្តថា “ទ្រព្យសម្បត្តិរបស់ខ្លួនមាន” នឹកចង់

បរិភោគចាយវាយកាលណា ក៏បានទាន់ចិត្តកាលនោះ លុះចាយចិញ្ចឹមខ្លួន-ប្រពន្ធ-កូន និងមនុស្សដែលគួរទំនុកបម្រុងទៅហើយ ក៏រមែងបានសេចក្តីសុខកាយសុខចិត្តជាងអ្នកក្រ ។ ព្រោះហេតុនោះបានជាទ្រព្យសម្បត្តិនោះ ជារបស់គឺបុគ្គលគប្បីប្រាថ្នាក្នុងខាងដើម ។ កាលបើមានទ្រព្យសម្បត្តិដែលជាប្រយោជន៍ក្នុងបច្ចុប្បន្នបរិបូណ៌ហើយងាយស្វែងរកប្រយោជន៍ក្នុងបរលោក និងប្រយោជន៍ក្នុងព្រះនិព្វានតទៅ ។

ឯទ្រព្យសម្បត្តិរបស់មនុស្សក្នុងលោក មានច្រើនបែបច្រើនយ៉ាងជាអនេកប្បការ មិនងាយនឹងស្គាល់ឈ្មោះសព្វគ្រប់បាន, តែបើនិយាយដោយសារុប្ប សំដៅយកតែទ្រព្យដែលជាមេធំ ៗ ឬជាកំណប់ទ្រព្យសំខាន់ៗដែលឲ្យសម្រេចសេចក្តីសុខកាយស្រួលចិត្តដល់បុគ្គលជាម្ចាស់ ឃើញទាន់ភ្នែកក្នុងលោកនេះ និងតាមជូនឲ្យបានសេចក្តីសុខកាយស្រួលចិត្តក្នុងភពខាងមុខតទៅទៀតនោះ មានតែ ៤ បំពូក(១)គឺ:

---

១-ន័យខ្លះថា មាន ២ យ៉ាងគឺ ធនទ្រព្យ ១ ភោគទ្រព្យ ១ ធនទ្រព្យបានខាងមាសប្រាក់, ភោគទ្រព្យ បានខាងគ្រឿងប្រើប្រាស់ផ្សេង ៗ ។ ន័យខ្លះថាមាន ២ យ៉ាង គឺ សវិញ្ញាណកទ្រព្យ ទ្រព្យមានវិញ្ញាណ ១ អវិញ្ញាណកទ្រព្យ ទ្រព្យឥតវិញ្ញាណ ១ ។

១- **ថាវរនិធិ** កំណប់ទ្រព្យនៅនឹងកន្លែង

២- **ជង្គមនិធិ** កំណប់ទ្រព្យដើរបាន

៣- **អង្គសមនិធិ** កំណប់ទ្រព្យនៅក្នុងខ្លួន

៤- **អនុគាមិកានិធិ** កំណប់ទ្រព្យជាប់តាមខ្លួនទៅ

ប្រាក់ មាស ស្រែ បម្ការ ច្បារដំណាំ ឬទ្រព្យណាៗ ដែលជាពួកទ្រព្យឥតវិញ្ញាណ កម្រើកឯង ៗ មិនបាន ហៅថា កំណប់ទ្រព្យនៅនឹងកន្លែង ។

ខ្ញុំកំដរ ឬ មនុស្សបម្រើ ប្រុស ស្រី គោ ក្របី ដំរី សេះ លា អូដ្ឋ រហូតដល់ទ្រព្យណា ៗ ដែលជាពួកទ្រព្យមានវិញ្ញាណ កម្រើកឯង ៗ បាន ហៅថាកំណប់ទ្រព្យដើរបាន ។

ការងារ សិល្ប វិទ្យា ឬបំណោះណា ៗ ដែលរៀនចេះចាំ បំណាំទុកក្នុងចិត្ត ហើយជាហេតុឲ្យសម្រេចការចិញ្ចឹមជីវិត បាន ហៅថា កំណប់ទ្រព្យនៅក្នុងខ្លួន ។

ទាន សីល ភាវនា ឬបុណ្យកុសលណា ៗ ដែលជាប់តាម ឲ្យផល ដូចស្រមោល ហៅថាកំណប់ទ្រព្យជាប់តាមខ្លួនទៅ ។

កំណាប់ទ្រព្យទាំង៤បំពួកនេះ បើបុគ្គលស្វែងរកបាន ហើយជាផលប្រយោជន៍ឲ្យកើតសេចក្ដីសុខក្នុងលោកនេះ និង លោកខាងមុខ ។ បានជាលោកឲ្យឈ្មោះថា "កំណាប់ទ្រព្យ" ព្រោះជារបស់ដែលបុគ្គល ត្រូវជីកគាស់រើឡើងដោយចបជ្រនីក គឺសេចក្ដីប្រឹងសង្វាតយ៉ាងខ្លាំង ឲ្យដូចជាគេជីកគាស់កំណាប់ ដែលកប់ក្នុងផែនដីទើបបាន, បើខ្ជិលប្រអូស មិនអាចនឹងគាស់ យកបានឡើយ ព្រោះហេតុនេះបានជា ព្រះអនាវរណញ្ញាណ ជាបរមគ្រូ កាលនឹងទ្រង់ត្រាស់ទេសនាអំពីសម្បទាទាំង ៤ ដែលជាហេតុឲ្យបានកំណាប់ទ្រព្យ ជាប្រយោជន៍ ឲ្យកើត សេចក្ដីសុខទាន់ភ្នែកក្នុងលោកនេះ ទ្រង់លើកយកឧដ្ឋាន-សម្បទា (ការបរិបូណ៌ដោយសេចក្ដីប្រឹងប្រែង) ឡើងសម្ដែង ជាប្រធាននៃសម្បទាទាំងពួង ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ប្រដៅថា អ្នកស្វែងរកទ្រព្យ សម្បត្តិដែលជាផលឲ្យបានសេចក្ដីសុខក្នុងជាតិនេះ ត្រូវ ប្រកបដោយហេតុគឺ សម្បទា ៤ យ៉ាងដូចពោលមកខាងដើម ដែលនឹងអធិប្បាយតទៅនេះ ៖

១- **ឧដ្ឋានសម្បទា** : កុលបុត្រក្នុងលោកនេះ សម្រេចការចិញ្ចឹមជីវិតដោយសេចក្តីប្រឹងសង្វាត, ធ្វើការងារណានីមួយ ទោះស្រែចម្ការក្តី ជំនួញក្តី ការចិញ្ចឹមគោ (ពាហនៈ ឬគោទឹកដោះ)ក្តី រាជការខាងទាហានក្តី រាជការខាងមន្ត្រីក្តី ជាងផ្សេង ៗ ក្តី ក៏ជាមនុស្សខ្នះខ្នែងក្នុងការងារនោះ ៗ មិនខ្ជិលច្រអូសនឹងប្រកបដោយសេចក្តីឆ្លៀវឆ្លាសក្នុងឧបាយដែលគួរធ្វើ គួរចាត់ចែង យ៉ាងនេះ ហៅថា ឧដ្ឋានសម្បទា ( ការបរិបូណ៌ដោយសេចក្តីប្រឹងសង្វាត ) ។

អត្ថរសនៃព្រះពុទ្ធដីកាដែលពោលមកខាងដើមនេះ ជាពាក្យបញ្ជាក់ដោយរួបរួមឲ្យដឹងថា ការរកស៊ីចិញ្ចឹមជីវិតរបស់មនុស្សក្នុងលោកមានតែប៉ុណ្ណោះ គឺធ្វើស្រែ, ធ្វើចម្ការ, ធ្វើជំនួញ ធ្វើការចិញ្ចឹមគោ, ធ្វើរាជការ, ធ្វើជាង ។ ការងារអម្បាលនេះ សុទ្ធតែជាកិច្ចត្រូវសម្រេចដោយអង្គ ២ គឺ សេចក្តីប្រឹងប្រែង ១ សេចក្តីប៉ិនប្រសប់ ១ ទោះបីការណាៗ ក៏ត្រូវតែប្រកបដោយអង្គ ២ ប្រការនោះ ៗ ទើបបានសម្រេច, គឺមុនដំបូងត្រូវប្រឹងរៀនបំណោះទាំងពួង មានអក្សរនិងលេខនពន្ធជាដើមឲ្យបេះឲ្យប៉ិន

ប្រសប់ក្នុងការទាំងពួង ហើយប្រឹងធ្វើប្រឹងរកតទៅ បើមិន ដូច្នោះ មិនបានសម្រេចទេ បើទុកជាបានសម្រេចខ្លះ ក៏មិនធំទូលំទូលាយ ។

ការងារគ្រប់បំពូក ដូចពោលមកខាងដើម សុទ្ធតែជាការនាំឲ្យកើតទ្រព្យសម្បត្តិដូចគ្នាទាំងអស់, អ្នកស្វែងរកទ្រព្យកុំគប្បីប្ដូលចិត្តថា ការណាស្រួលជាងការណា ; ត្រូវប្ដូលចិត្តថាទោះបីការងារណា ៗ ក៏ដោយ សុទ្ធតែនឿយហត់គ្រប់ឥរិយាបថដូចគ្នា ឥតមានការងារណាមួយដែលនៅស្ងៀម ៗ ស្រាប់តែបានទ្រព្យសម្បត្តិងាយ ៗ នោះទេ ដូចខ្លានៅក្នុងព្រៃមិនមែននៅស្ងៀម ៗ ស្រាប់តែមានម្រឹគរត់ចូលមាត់នោះឡើយ ។ ព្រោះហេតុនេះទើបមានពុទ្ធភាសិតដាស់តឿនថា **"កយិរា ចេ កយិរាថេនំ** បើបុគ្គលតាំងចិត្តធ្វើការអ្វី ត្រូវតែប្រឹងធ្វើការនុ៎ះឲ្យមែនទែន កុំបណ្ដែតបណ្ដោយ" គឺកុំធុញទ្រាន់នឹងការងារដែលត្រូវធ្វើកុំអាងហេតុខ្ជិល ៦ យ៉ាង គឺថាព្រឹកណាស់ , ល្ងាចណាស់ , ក្ដៅណាស់ ត្រជាក់ណាស់ , ស្រេកណាស់ ឃ្លានណាស់ ; ហេតុណាមួយជាលេសហើយបន្ធូរបន្ថយ ឬបញ្ឈប់ការងារនោះឡើយ ។

មានពុទ្ធភាសិតគាថាដាស់តឿនថា

**ភាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា**
**និប្ផន្នសោភិនោ អត្ថា ខន្ត្យា ភិយ្យោ ន វិជ្ជតិ**

ធម្មតាមនុស្សដែលមាន ជាតិជាបុរស ត្រូវតែព្យាយាម គ្រាតែបានសម្រេចប្រយោជន៍, ប្រយោជន៍ដែលនឹងសម្រេចដោយល្អទៅបាន មិនមានអ្វីក្រៃលែងជាងសេចក្តីធន់ទ្រាំឡើយ ។

ឯសេចក្តីព្យាយាមក្នុងការស្វែងរកទ្រព្យសម្បត្តិ មានច្រើនយ៉ាង មានព្យាយាមធ្វើ ព្យាយាមសន្សំជាដើម, សេចក្តីព្យាយាមធ្វើ និងព្យាយាមសន្សំ ជាគុណជាតដ៏សំខាន់ក្នុងការបង្កើនទ្រព្យសម្បត្តិឲ្យកើនឡើងពីតិច ៗ សន្សំម ៗ ទៅរកច្រើន ។

ក្នុងជាតកមានដំណាលអំពីបុរសម្នាក់ ជាឧបដ្ឋាកចុល្លកសេដ្ឋី រើសកណ្តុរស្លាប់មួយ យកទៅលក់ឲ្យអ្នកចិញ្ចឹមឆ្មាបានតម្លៃ១ កាកណិក សន្សំទុកធ្វើជាទុនលក់ដូរត ៗ ទៅដរាបដល់បានទ្រព្យ ២ សែនកហាបណៈ ក្នុងទីបំផុតបាន

ឡើងបានត្រូវជាសេដ្ឋី ។ ព្រោះការព្យាយាមសន្សំមានអានិសង្ស ដូច្នេះ បានជាព្រះបោរាណាចារ្យនិព័ន្ធជាគាថា ថា :

**អប្បកេនបិ មេធាវី ចាភតេន វិចក្ខណោ**
**សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមំ**

អ្នកមានប្រាជ្ញាឆ្លៀវឆ្លាស រមែងតាំងខ្លួនជាអ្នកមានទ្រព្យសម្បត្តិ ដោយដើមទុនតិចតួច ដូចគេបង្កាត់ភ្លើងតូចឲ្យឆេះធំឡើងបាន ។

ព្រះបោរាណាចារ្យនាំរឿងនេះមកដំណាល ដើម្បីបង្ហាញឲ្យឃើញជាបែបយ៉ាង ដល់អ្នកដែលចូលចិត្តរកទ្រព្យដោយផ្លូវជំនួញ ។

អង្គរបស់អ្នកជំនួញមាន ៣ គឺ :

| | |
|---|---|
| **១- ចក្ខុមា** | ជាអ្នកមានបញ្ញាចក្ខុ |
| **២- វិធុរោ** | ជាអ្នកមានព្យាយាមដ៏ប្រសើរ |
| **៣- និស្សយសម្បន្នោ** | ជាអ្នកសម្បូណ៌ដោយបុគ្គលជាទីពឹង |

សឹងមានពុទ្ធភាសិតជាសំអាងថា :

**តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ ចាបណិកោ នចិរស្សេវ មហន្តត្តំ វេបុលត្តំ ចាបុណាតិ ភោគេសុ កតមេហិ តីហិ ឥធ ភិក្ខវេ ចាបណិកោ ចក្ខុមា ច ហោតិ វិធុរោ ច និស្សយសម្បន្នោ ច ។**

ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារដែលប្រកបដោយអង្គ ៣ គឺ ជាអ្នកមានបញ្ញាចក្ខុ ១ ជាអ្នកមានព្យាយាមដ៏ប្រសើរ ១ ជាអ្នកសម្បូណ៌ដោយបុគ្គលជាទីពឹង ១ មិនយូរប៉ុន្មានគង់នឹងបានទៅជាអ្នកធំទូលាយដោយភោគសម្បត្តិ ។

ត្រង់អង្គទី ១ ដែលថា "ជាអ្នកមានបញ្ញាចក្ខុ" នោះគឺត្រូវជាអ្នកមានប្រាជ្ញា ។ ហេតុដែលឲ្យកើតប្រាជ្ញាមាន ៣ យ៉ាង គឺការស្តាប់ ១ ការគិត ១ ការបម្រើន១, អ្នកដែលត្រូវការរកទ្រព្យដោយផ្លូវលក់ដូរឬដោយផ្លូវជំនួញ ត្រូវឧស្សាហ៍ស្តាប់ពាក្យពន្យល់ ពាក្យទូន្មាន ដោយយកចិត្តទុកដាក់ អំពីសំ-ណាក់អ្នកជំនួញឲ្យរឿយ ៗ ឲ្យដឹងបែបបទស្ទាត់ជំនាញក្នុងការជួញជាមុន ដូចដឹងថ្លៃទំនិញជាដើម, ត្រូវរៀនក្នុងសាលា

បង្រៀនផ្លូវជំនួញ ឬត្រូវរៀនក្នុងផ្ទះអ្នកជំនួញណាមួយដែលគេស្ទាត់មកយូរហើយ កាលបើបានស្ដាប់បានរៀនដូចពោលមកនេះរមែងកើតប្រាជ្ញា ។ យ៉ាងនេះ ហៅថា ប្រាជ្ញាកើតអំពីការស្ដាប់ការរៀន ។ ឯការគិតនោះ គឺអ្នកផ្សារឬអ្នកជំនួញត្រូវត្រិះរិះឈ្លេចឈ្លីរាវរកហេតុផលក្នុងការលក់ដូរ ឲ្យច្បាស់លាស់ឲ្យយល់ប្រាកដថាចំណេញតិចច្រើនឬខាត បើគិតខ្លួនឯងមិនឃើញត្រូវសាកសួរអ្នកដែលធ្លាប់ចាត់ការជំនួញ ឲ្យស្រេចជាមុនសិនសឹមចាត់ការធ្វើដូចភាសិតបុរាណថា “គិតរួចសឹមគូរ” គឺការអ្វី ៗ ក៏ដោយ ត្រូវតែគិតឲ្យដឹងខាតដឹងចំណេញជាមុនសឹមធ្វើ, កាលបើគិតត្រិះរិះយ៉ាងនេះជាដើម រមែងកើតប្រាជ្ញា។ យ៉ាងនេះ ហៅថា ប្រាជ្ញាកើតអំពីការគិត ។ ឯការចម្រើននោះ គឺការធ្វើរឿយ ៗ, បើធ្វើម្ដងម្កាលមិនហៅថាចម្រើនទេ លុះតែធ្វើច្រើនដង ច្រើនគ្រា ឬធ្វើញយ ៗ ទើបហៅថាចម្រើន គឺធ្វើហើយធ្វើទៀតដរាបដល់ធ្លាប់នោះឯង, បើធ្លាប់ធ្វើការញយ ៗ ការនោះរមែងប្រាប់អ្នកធ្វើ ឲ្យយល់បន្តិចម្ដង ៗ ការមុនជាគំរូឲ្យការក្រោយ ដូចអ្នកដែលធ្លាប់ធ្វើជំនួញណាមួយយូរមកហើយ

សេចក្ដីឆ្លៀវឆ្លាសតែងមកប្រាកដដល់បិត្តគេ ឲ្យគេដឹងដល់ជំនាញឯទៀតផ្សេង ៗ ជាលំដាប់ទៅបាន, អ្នកមិនធ្លាប់ធ្វើ តែងមានសេចក្ដីងេងងោង មិនឈ្លាសក្នុងរឿងជំនាញទេ, ទោះបីអ្នកដែលបានរៀនស្ទាត់ជំនាញ ក្នុងសាលាជំនាញហើយក៏ដោយតែបើមិនទាន់ធ្លាប់ធ្វើ ក៏មិនអាចដឹងការសព្វគ្រប់បាន, លុះតែធ្លាប់ធ្វើរឿយៗ ទើបកាន់តែយល់ការច្រើន ៗ ឡើង ។ យ៉ាងនេះ ហៅថាប្រាជ្ញាកើតអំពីការបម្រើន ។ អ្នកជំនាញដែលមានការស្ដាប់ ការរៀន ការបម្រើន ដូចពោលមកនេះរមែងរកទ្រព្យសម្បត្តិបានធំទូលាយ ។

គ្រង់អង្គទី ២ ដែលថា"ជាអ្នកមានព្យាយាមដ៏ប្រសើរ" នោះ គឺអ្នកផ្សារឬអ្នកជំនាញត្រូវប្រកបដោយសេចក្ដីព្យាយាមបាត់បែងការងារក្នុងផ្ទះ ក្រៅផ្ទះ, ឯព្យាយាមបាត់បែងការក្នុងផ្ទះនោះគឺ ព្យាយាមត្រួតត្រាបញ្ជី ព្យាយាមត្រួតត្រារបស់ជាគ្រឿងលក់ដូរគ្រប់ចំពូកព្យាយាមរិះរកឧបាយរៀបចំផ្ទះសម្បែងយ៉ាងណាឲ្យខាងតែស្អាតបាត ឲ្យមានរបៀបរៀបរយល្អប្លែកឲ្យស្នុះខ្លោតជាងគេ ដើម្បីឲ្យអ្នកដំណើរឬអ្នកដើររកទិញទំនិញ

គេក្រឡេកឃើញពីចម្ងាយ ចង់ដើរចូលទៅជិតឈ្ងោកមើល ហើយមើលទៀត, ព្យាយាមរៀបរបស់តិចឲ្យគេមើលទៅឃើញច្រើនតែឲ្យមានរបៀបល្អ កុំដាក់តាមតែបាន, បើនៅក្នុងទីដែលមានផ្ទះអ្នកលក់ដូរដូចគ្នាច្រើន ត្រូវព្យាយាមសរសេរស្លាក ឬបោះសំបុត្រផ្សាយដំណឹង ឲ្យគេដឹងច្រើនគ្នា ដើម្បីឲ្យគេស្គាល់ឈ្មោះខ្លួន និងស្គាល់ឈ្មោះទំនិញរបស់ខ្លួនថាមានអ្វីខ្លះដោយឆាប់រហ័ស, នេះជាការងារក្នុងផ្ទះ ។ ចំណែកព្យាយាមបាត់បែងការងារក្រៅផ្ទះនោះ គឺព្យាយាមរកទំនិញប្លែក ៗ អំពីទីផ្សេង ៗ ដែលជារបស់ត្រូវចិត្តជនានុជនមកទុកលក់ ឲ្យច្រើនបែបច្រើនយ៉ាង ឬរបស់ណាដែលប្លែក បើយល់ឃើញថាជាទីនិយមរបស់មហាជន ដូចផ្លែឈើទុំដំបូង ឬទំនិញអ្វីដែលដល់ដំបូងជាដើម ក៏ត្រូវព្យាយាមរកមកទុកក្នុងផ្ទះឲ្យបានមុនគេ ។ អ្នកលក់ដូរដែលមានព្យាយាមដូចពោលមកនេះជាដើម រមែងចម្រើនទ្រព្យសម្បត្តិធំទូលាយដោយរហ័ស ។

ត្រង់អង្គទី ៣ ដែលថា "ជាអ្នកសម្បូណ៌ដោយបុគ្គលជាទីពឹង" នោះ គឺអ្នកជំនួញ ត្រូវគប់រកមនុស្សដែលជាអ្នក

មានទ្រព្យ មានយសស័ក្តិជាមិត្តសំឡាញ់ក្លើម្រាក់ឲ្យច្រើននាក់ ទើបស្រួល ព្រោះអ្នកអស់នោះគេនឹងជួយផ្សាយជួយផ្គងផ្តើម ជួយចេញធនធានជាដើមទុន ជួយទំនុកបំរុងក្នុងគ្រាដែលមានហេតុភេទផ្សេងៗ កើតឡើង, ត្រូវជាអ្នកមានពាក្យសម្តីស្រទន់ផ្អែមល្ហែមពីរោះក្បោះក្បាយ រួសរាយរាក់ទាក់ចៅរ៉ៅទៅរកជនានុជនដែលគេមកររកខ្លួនឬខ្លួនទៅរកគេ កុំធ្វើឫកក្រអឺតក្រអោងបោងហោងកោងកាច ទើបអ្នកផងគេស្រឡាញ់ពេញចិត្តច្រើន, ត្រូវជាមនុស្សមានគំនិតមារយាទសុចរិតស្លូតត្រង់ល្អ កុំជាមនុស្សមានឈ្មោះអាក្រក់ដោយលេងល្បែងផ្សេងៗមានល្បែងភ្នាល់ជាដើម ត្រូវជាអ្នកចាយទ្រព្យល្មមប្រមាណ កុំរិះពេកកុំកញ្ចះកញ្ចាយពេក, ទើបអ្នកមានទ្រព្យច្រើន ៗ គេហ៊ានជួយផ្គងផ្តើមដោយកិច្ចផ្សេង ៗ មានជួយទ្រព្យជាដើមទុនជាដើម ។ អ្នកជំនួញដែលមានបុគ្គលជាទីពឹងអាស្រ័យច្រើនរមែងចម្រើនទ្រព្យសម្បត្តិធំទូលាយដោយរហ័ស ។ ទោះអ្នកធ្វើស្រែក្តី ចម្ការក្តី ជំនួញក្តី ការឈ្នួលក្តី ការរាជការក្តី ការជាងក្តី ដែលនឹងចម្រើនទ្រព្យសម្បត្តិធំទូលាយទៅបាន ក៏ដោយសារតែសេចក្តី

ព្យាយាម និងសេចក្ដីឆ្លៀវឆ្លាសដូចពោលមកខាងដើមនេះដែរ, ហេតុនេះ បានជាមានពុទ្ធភាសិតថា"**ឧដ្ឋាតា វិន្ទតេ ធនំ** អ្នកមានព្យាយាមរមែងបានទ្រព្យ" ។

ពុទ្ធភាសិតនេះសមនឹងខេមរភាសិតបុរាណថា"បេះពីរៀន មានពីរក ក្រពីខ្ជិល" ។ ប៉ុន្តែ សេចក្ដីព្យាយាមរបស់ឯកជនតែម្នាក់ឯង រមែងមានផលតិចជាងសេចក្ដីព្យាយាមរបស់ពួកជនដែលរួមគ្នាជាពួកក្រុម អ្នកមានប្រាជ្ញាគួរសង្កេតមើលសត្វ ៣ បំពូកគឺ ឆ្កែញាំងបំពូក ១ កណ្ដៀរបំពូក ១ ឃ្មុំបំពូក ១ សត្វ ៣ បំពូកនេះបើសង្កេតគង់នឹងដឹងថាប្លែកគ្នា គឺឆ្កែញាំងវាសន្សំដីយកមកធ្វើសម្បុកដោយព្យាយាមណាស់ដែរ តែវាធ្វើតែម្នាក់ ៗ វាទើបសម្បុករបស់វាមានសណ្ឋានតូច ៗ នៅបានតែម្នាក់ឯង, ឯកណ្ដៀរឬឃ្មុំវាសន្សំដីយកមកធ្វើដំបូក ឬសន្សំផ្កាឈើយកមកធ្វើសម្បុកដោយព្យាយាមនិងសាមគ្គីរួបរួមគ្នាច្រើនទើបបានដំបូកឬសម្បុករបស់វាមានសណ្ឋានធំ ៗ ជាផ្ទះសម្បែងយ៉ាងស្ដុកស្ដម្ភរបស់វា អាចនាំញាតិមិត្តដែលរួមជាតិជាមួយគ្នាជ្រកអាស្រយ័នៅឲ្យកើតសេចក្ដីសុខកាយ សប្បាយចិត្តទៅបាន ។

មានពុទ្ធភាសិតសម្ដែងហេតុនៃសេចក្ដីសុខថា៖

**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

សេចក្ដីព្រមព្រៀងរបស់ជនដែលរួមគ្នាជាពួកក្រុម ជាហេតុឲ្យកើតសេចក្ដីសុខ, សេចក្ដីព្យាយាមរបស់ពួកអ្នកមានសេចក្ដីព្រមព្រៀង ជាហេតុឲ្យកើតសេចក្ដីសុខ ។

សំណៅពុទ្ធភាសិតនេះ ចង្អុលប្រាប់ហេតុផលច្បាស់លាស់ថា "សេចក្ដីព្យាយាមរបស់មនុស្សគ្នាតិច មិនមានផលប្រសើរស្មើនឹងសេចក្ដីព្យាយាមរបស់មនុស្សគ្នាច្រើនឡើយ"។

ការប្រឹងប្រែងដូចពោលមកនេះ ហៅថា ឧដ្ឋានសម្បទា (ការបរិបូណ៌ដោយព្យាយាម) ឧដ្ឋានសម្បទានេះ ជាធម៌មានអានុភាព អាចធ្វើបុគ្គលឲ្យតាំងខ្លួនជាអ្នកមានទ្រព្យស្ដុកស្ដម្ភបាន ព្រោះហេតុនេះ បានជាព្រះត្រៃលោកនាថជាបរមគ្រូទ្រង់លើកឡើងសម្ដែងជាប្រមុខនៃសម្បទាទាំងពួង ។

២- **អារក្ខសម្បទា** : កាលបើកុលបុត្រស្វែងរកទ្រព្យសម្បត្តិដោយកម្លាំងកាយ ប្រឹងធ្វើការងារបែកញើសហូរញើស និងកម្លាំងគំនិតប្រាជ្ញា ខំរិះរកឯរាបដល់បានជាទ្រព្យកើតឡើង

ដោយធម៌ហើយ ក៏ថែរក្សាមិនឲ្យខូចអន្តរាយដោយភ័យផ្សេងៗ គឺរាជភ័យ ចោរភ័យ អគ្គិភ័យ ឧទកភ័យ និងអ្នករួមមត៌កជាមួយគ្នា, ដោយបានគិតប្រុងទុកក្នុងចិត្តជានិច្ចថា "ធ្វើម្ដេចហ្ន៎ កុំឲ្យរាជការរឹបយក គឺកុំឲ្យលក់ពិន័យ (ឬឡាយឡុង) ទៅបាន កុំឲ្យចោរលួចប្លន់យកបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកលិចបាន កុំឲ្យមនុស្សអ្នករួមមត៌កជាមួយគ្នា ដែលមិនគាប់ចិត្តគ្នាដណ្ដើមយកទៅបាន "យ៉ាងនេះហៅថា" អារក្ខសម្បទា (ការបរិបូណ៌ដោយការរក្សា) ", អារក្ខសម្បទានេះ មានអានុភាពសំខាន់ខាងឯធ្វើទ្រព្យសម្បត្តិទាំងពួងឲ្យគង់នៅ ។

អ្នកដែលមានបំណងនឹងថែរក្សាទ្រព្យឲ្យបិតថេរ ត្រូវដឹងវិធីរក្សា, ឯវិធីរក្សានោះមាន ៤ យ៉ាង គឺ

១- ចេះស្វែងរករបស់ដែលបាត់,

២- ចេះជួសជុលរបស់ដែលចាស់គ្រាំគ្រា ,

៣- បរិភោគល្មមប្រមាណ,

៤- មិនតាំងស្ត្រីឬបុរសទ្រុស្តសីលជាធំ ។

ធម្មតាទ្រព្យដែលនឹងគង់នៅ ឬនឹងចម្រើនឡើងបាន ក៏ដោយសារតែម្ចាស់ទ្រព្យចេះរក្សា ចេះចាយ ចេះប្រើ ។

ឯការរក្សានោះ គប្បីកំណត់ដោយអាការដូច្នេះគឺ ចេះទុកដាក់, ចេះថ្នម, ចេះជួសជុលថែមបំពេញ, ចេះស្តាយ, ចេះធ្វើឱ្យមានផលតទៅ ។

ត្រង់ពាក្យថា "ចេះទុកដាក់" គឺចេះរកទីទុកដាក់ដ៏មាំមួនឱ្យឃ្លាតចាកភ័យផ្សេង ៗ មានចោរភ័យជាដើម សូម្បីទុកដាក់ក្នុងផ្ទះសម្បែងក៏ត្រូវប្រយត្ន័ជានិច្ច នឹងទុកដាក់ឱ្យសមគួរតាមបែបរបស់ទ្រព្យ, ទ្រព្យណាដែលគួរដាក់ខាងក្រៅក៏ដាក់ខាងក្រៅ, ទ្រព្យណាគួរដាក់ខាងក្នុងក៏ដាក់ខាងក្នុង ឱ្យមានរបៀបរៀបរយ កុំចោលរាត់រាយដូចអ្នកខ្លះផ្ទះធំទូលាយល្អពេក តែមិនដឹងរបៀបរៀបចំទ្រព្យសម្បត្តិ ក៏ទៅជាចង្អៀតចង្អល់ ស្មុកស្មះមិនល្អមើល ព្រោះទុកដាក់ផ្តេសផ្តាស ។

ត្រង់ពាក្យថា "ចេះថ្នម"គឺពួករបស់ដែលជាគ្រឿងធ្លាប់ដាច់ដាចឬចាស់គ្រាំគ្រាដូចសំពត់ជាដើម ក៏ចេះថែរក្សាឱ្យល្អ ពួករបស់ជាលោហធាតុដែលជាគ្រឿងធ្លាប់មានស្នឹមស្វារប្រែះ

ចាប់ ដូចគ្រឿងដែកឬស្ពាន់ជាដើម ដែលមិនទាន់ប្រើ ក៏បេះទុកដាក់បិទបាំងមិនឲ្យហាលអាកាស, ដែលកំពុងប្រើក៏ឧស្សាហ៍ជុសខាត់ឲ្យស្អាតជានិច្ច, ពួករបស់ដែលជាគ្រឿងស្រួយ ដូចពែងប៉ាន់កែវជាដើម វេលានឹងចាប់កាន់ ក៏ចាប់កាន់ដោយថ្និតថ្នម ប្រយ័ត្នមិនឲ្យភ្លាត់របូតធ្លាក់ នឹងជូតសម្អាតឲ្យស្អាតជាដរាប ។

ត្រង់ពាក្យថា "បេះជួសជុលថែមបំពេញ" គឺផ្ទះសម្បែងឬវត្ថុក្នុងផ្ទះក្រៅផ្ទះ ដែលទ្រុឌទ្រោមទ្រេតទ្រោត ក៏ជួសជុលទល់ទ្រឲ្យល្អដូចប្រក្រតី, គ្រឿងចក្រគ្រឿងម៉ាស៊ីនមាននាលិកាជាដើមដែលខូច ក៏បេះកែខ្លួនឯង ឬឲ្យគេកែឲ្យល្អដូចដើម គ្រឿងឈើមានតុទូកៅអីជាដើមដែលនៅថ្មី ក៏ឧស្សាហ៍បោសសម្អាតជុសខាត់ឲ្យស្អាតល្អជាដរាប, ដែលបាក់បែកឬប្រឡាក់ប្រឡូស ក៏ជួសជុលជុសខាត់សម្អាតឲ្យស្អាតល្អដូចប្រក្រតី ។

មានពុទ្ធភាសិតគាថា ថា៖

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ**

មន្ត គឺការរៀនសូត្រ មានការមិនសូធ្យាយជាមន្ទិល, ផ្ទះមានការមិនជួសជុលជាមន្ទិល, សេចក្តីខ្ជិលជាមន្ទិលរបស់ពណ៌សម្បុរ, សេចក្តីប្រហែសធ្វេសជាមន្ទិលរបស់ការរក្សា ។

ត្រង់ពាក្យថា "បេះស្តាយ" គឺរបស់ដែលមិនទាន់ខូចមិនគួរបណ្តោយឲ្យខូច ដែលខូចហើយតែនៅគួរប្រើបានមិនគួរបោះបង់ចោល, តែកុំស្តាយជ្រុលពេក ដែលរាប់បញ្ចូលទៅក្នុងពួកកំណាញ់ រហូតដល់មិនហ៊ានបរិភោគប្រើប្រាស់ស៊ីចាយនោះឡើយ, គប្បីចាយឲ្យសមតាមកម្លាំងទ្រព្យ ដូចត្រង់បទថាសមជីវិតា នោះឯង ដែលនឹងមានសម្តែងទៅក្នុងខាងមុខ ។

និទានមានដំណាលប្រារព្ធរឿងអ្នកកំណាញ់ជ្រុលថា៖

មានសេដ្ឋីម្នាក់ឈ្មោះអបុត្តកសេដ្ឋី ជាសេដ្ឋីឥតកូន មានទ្រព្យច្រើន តែជាមនុស្សកំណាញ់ជ្រុលពេក ស៊ូអត់ស៊ូឃ្លាន មិនហ៊ានចាយទ្រព្យសម្បត្តិបរិភោគប្រើប្រាស់ ធ្វើខ្លួនឲ្យថោកទាបដូចអ្នកក្រ, លុះស្លាប់ទៅ សម្បត្តិនោះធ្លាក់ទៅជាព្រះរាជ-ទ្រព្យទាំងអស់ ។ ព្រះបាទបសេនទិកោសលទ្រង់ស្តេចទៅគាល់ព្រះបរមសាស្តា ទូលរឿងនោះ, ព្រះអង្គក៏សម្តែងបុព្វកម្ម

របស់សេដ្ឋីនោះថា "ដែលបានជាសេដ្ឋីព្រោះអំណោយទាន ដែលប្រើមនុស្សឲ្យដាក់បាត្រព្រះបច្ចេកពុទ្ធ ព្រះនាមតគរសិខី ដែលមានសម្បត្តិហើយមិនបានជាប្រយោជន៍ខ្លួន ព្រោះទោស នៃសេចក្ដីកំណាញ់អំពីកាលក្រឡេកឃើញបង្អាក់ ដែលខ្លួនឲ្យ គេដាក់បាត្រនោះល្អ ក៏នឹកស្ដាយថា "មិនគួរយកទៅប្រគេន លោកសោះ គួរទុកឲ្យខ្ញុំកំដរវិញល្អជាង " ។ កាលសេដ្ឋីនោះ ស្លាប់ទៅ ទៅឆេះក្នុងមហារោរុវនរក ព្រោះទោសសេចក្ដី កំណាញ់និងទោសសម្លាប់ម្ចាស់ទ្រព្យយកសម្បត្តិគេ " ។

មានពុទ្ធភាសិតសម្ដែងប្រារព្ធរឿងនេះថា ៖

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**
**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**

ភោគសម្បត្តិទាំងឡាយ រមែងសម្លាប់មនុស្សអ្នកមាន ប្រាជ្ញាអាក្រក់ តែមិនសម្លាប់មនុស្សអ្នកស្វែងរកត្រើយ គឺ ព្រះនិព្វានឡើយ មនុស្សអ្នកមានប្រាជ្ញាអាក្រក់រមែងសម្លាប់ ខ្លួនឯងដូចសម្លាប់អ្នកដទៃ ព្រោះបង់បានភោគសម្បត្តិ ។

ព្រះបោរាណាចារ្យនាំរឿងនេះមកសម្តែង ដើម្បីបង្ហាញបែបយ៉ាងឲ្យឃើញថា មនុស្សដែលកំណាញ់ទ្រព្យមិនត្រូវ-បែប ទោះបីមានទ្រព្យច្រើន ក៏ឋោកទាបមិនថ្លៃថ្លា ដូចភាសិតបុរាណថា “កំណាញ់ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍ យស” នោះឯង ។

ត្រង់ពាក្យថា “បេះធ្វើឲ្យមានផលតទៅ” គឺ ដូចមានស្រែចម្ការ បានធ្វើខ្លួនឯង ឬឲ្យគេធ្វើ, មានប្រាក់កាស បានយកចេញមកចាយធ្វើដើមទុន ក្នុងការរកស៊ីទាំងពួងមានជំនួញជាដើម ។

ការបេះរក្សាទ្រព្យ ដូចពោលមកខាងលើនេះ ហៅថា អារក្ខសម្បទា (ការបរិបូណ៌ដោយការរក្សា) អារក្ខសម្បទានេះ ជាធម៌មានអានុភាពដ៏សំខាន់ ខាងឯធ្វើទ្រព្យដែលកើតពីឧដ្ឋានសម្បទា (ការប្រឹងរក) នោះឲ្យគង់នៅយឺនយូរនឹងឲ្យមានកម្រៃចម្រើនតទៅ ។ ព្រោះហេតុនេះបានជាព្រះដ៏មានបុណ្យជាបរមគ្រូ ទ្រង់លើកឡើងសម្តែងជាលំដាប់ទី ២ រងអំពីឧដ្ឋានសម្បទា ដើម្បីធ្វើឧដ្ឋានសម្បទាឲ្យមានផល ។

៣- **កល្យាណមិត្តតា ៖** កុលបុត្រអ្នកអាស្រ័យទៅក្នុងស្រុកឬនិគមមួយ ៗ ដែលមានពួកគហបតី ជាមនុស្សក្មេងតែមានកិរិយាមារយាទសណ្ដាប់ធ្នាប់បែបចាស់ ឬមនុស្សចាស់ដែលមានកិរិយាមារយាទជាមនុស្សចាស់មែនទែនគឺជាមនុស្សបរិបូណ៌ដោយសទ្ធាសីលៈ ចាគៈ បញ្ញាក៏បានភប់ប្រសព្វរាប់រកនិយាយស្ដីចរចាប្រឹក្សាសាកសួរសិក្សាគតិលោកគតិធម៌ ចម្លងរបៀបបែបផែនរបស់ជនអម្បាលនោះ, កាលបើធ្វើដូច្នោះរមែងជាមនុស្សមានសទ្ធាសីលៈចាគៈបញ្ញាទៅតាមគេ ។ យ៉ាងនេះហៅថាកល្យាណមិត្តតា (សភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ)

ការគប់មិត្តល្អរមែងមានអានិសង្ស‌ឲ្យកើតត្រៃពិធសម្បត្តិគឺសម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន, ការគប់មិត្តពាលរមែងមានទោសឲ្យវិនាសសម្បត្តិទាំងនោះ នឹងនាំឲ្យប្រព្រឹត្តអបាយមុខ៤យ៉ាង គឺឥត្ថីធុត្តោ អ្នកលេងស្រី,សុរាធុត្តោ អ្នកលេងសុរា អក្ខធុត្តោ អ្នកលេងល្បែងភ្នាល់, ការប្រព្រឹត្តិអបាយមុខទាំង ៤ យ៉ាងនេះ ទ្រព្យសម្បត្តិណាដែលមិនទាន់កើត ក៏មិនកើតឡើង ដែលកើតឡើងហើយក៏អន្តរធានទៅ

កុំបាច់និយាយដល់ទ្រព្យសម្បត្តិបន្តិចបន្តួច សូម្បីប្រើនរាប់រយលានក៏សល់នៅមិនបាន លោកប្រៀបដូចបឹងណាដែលមានផ្លូវបង្ហូរទឹកចូលតែមួយ មានផ្លូវបង្ហូរបេញច្រើន បឹងនោះរមែងរីងស្ងួតហួតហែងទៅដោយឆាប់រហ័ស ដរាបដល់អស់រលីងឥតមានសេសសល់, ត្រង់បទនេះ គួរឃើញដល់មនុស្សដែលបេះតែបាយមិនបេះរក ។

និទានមានដំណាលថា៖

មានសេដ្ឋីបុត្តម្នាក់បានទទួលទ្រព្យ ជាសម្បាប់អំពីមាតាបិតាដល់ ៨០ កោដិ ខាងប្រពន្ធក៏ដូចគ្នា រួមជា ១៦០ កោដិ តែសេដ្ឋីបុត្តនោះ ជាមនុស្សកញ្ជះកញ្ជាយបាយវាយឥតបទគប់តែនឹងមនុស្សអ្នកលេងសុរា ប្រព្រឹត្តអបាយមុខគ្រប់យ៉ាងរកតែស្រីរបាំមកបម្រើខ្លួន ឡើរង្វាន់ម្នាក់ៗ ច្រើនៗ ដល់ទីបំផុតក៏អស់ទ្រព្យ ត្រឡប់ជាអ្នកដើរសុំទានគេ ។ ថ្ងៃ ១ ព្រះបរមសាស្ដាទ្រង់ទតឃើញសេដ្ឋីបុត្តទាំងប្ដីប្រពន្ធ កំពុងឈរក្បែរទ្វារសាលាចាំទទួលអាហារសំណល់ ដែលភិក្ខុសាមណេរឲ្យទាន ក៏ទ្រង់ត្រាស់នឹងព្រះអានន្ទដោយព្រះគាថា ថា៖

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្វលេ។**
**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**សេន្តិ ចាចាតិខីណាវ បុរាណានិ អនុត្ថុនំ ។**

ពួកមនុស្សពាលដែលមិនប្រព្រឹត្តព្រហ្មចរិយធម៌មិនបាន ខំរកទ្រព្យក្នុងវេលាខ្លួននៅជាកម្លោះក្រមុំ រមែងក្រៀមក្រំដូច ក្រៀលចាស់ក្រៀមក្រំនៅលើភក់ដែលអស់ត្រី, ពួកមនុស្ស ពាលដែលមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានខំរកទ្រព្យក្នុង វេលាខ្លួននៅជាកម្លោះក្រមុំ រមែងដេកដកដង្ហើមធំស្តាយទ្រព្យ ចាស់ដែលអស់ទៅ ដូចព្រួញដែលគេបាញ់ទៅចាកបំពង់ ។

ព្រះបោរាណាចារ្យនាំរឿងនេះមកដំណាល ក៏ដើម្បីជាដំ-ណឹងដល់ជនដែលប្រាថ្នារក្សាទ្រព្យសម្បត្តិ ឲ្យដឹងថាការសេព គប់មិត្តពាលនាំឲ្យប្រព្រឹត្តអបាយមុខ, ការប្រព្រឹត្តអបាយមុខ ជាហេតុ ឲ្យខូចទ្រព្យសម្បត្តិដូចពោលមកនោះឯង, ការប្រព្រឹត្ត អបាយមុខនោះ ទោះបីមិនខូចទ្រព្យសម្បត្តិអស់រលីង ដល់ទៅ ដើរសុំទានគេដូចសេដ្ឋីនោះ ក៏គង់តែនាំឲ្យខូចកាសប្រាក់ធ្លាក់

ខ្លួនទៅជាមនុស្សបំពាក់គេច្រើន គេទារជុំវិញខ្លួន នាំឲ្យឋោកទាបខ្លួន មិនមានតម្លៃ, ម្ល៉ោះហើយ ក៏ប្រព្រឹត្តទុច្ចរិតផ្សេង ៗ ដើម្បីចិញ្ចឹមជីវិតឲ្យតែបានរស់ មិនគិតដល់បាបបុណ្យគុណទោសខុសត្រូវឡើយ ។ ការវៀរចាកអបាយមុខទាំង ៤ មានមិនសេពគប់មិត្តពាលជាដើម គប់រកតែមនុស្សល្អជាមិត្តភ័ក្តិ ហៅថាកល្យាណមិត្តតា (សភាពជាបុគ្គលមានមិត្តសំឡាញ់ល្អ) កល្យាណមិត្តតានេះមានអានុភាពដ៏សំខាន់ ខាងឯគ្រប់គ្រងទ្រព្យសម្បត្តិ ដែលបានមកពីឧដ្ឋានសម្បទា និងអារក្ខសម្បទា (ការព្យាយាមនិងការរក្សាទុក) នោះ ឲ្យរឹងរឹតតែឋិតថេរមាំមួនឡើង ។ ព្រោះហេតុនេះ បានជាព្រះបរមគ្រូទ្រង់លើកឡើងសម្តែងជាលំដាប់ទី ៣ រងអំពីឧដ្ឋានសម្បទា និងអារក្ខសម្បទាមក ដើម្បីជួយឧបត្ថម្ភឧដ្ឋានសម្បទា និងអារក្ខសម្បទានោះឲ្យរឹងប៉ឹងឡើង ។

៤- **សមជីវិតា** : កុលបុត្រដឹងហេតុចម្រើន និងហេតុវិនាសរបស់ទ្រព្យសម្បត្តិ ដូចដឹងថា “សេចក្តីចម្រើន នឹងគ្របសង្កត់សេចក្តីវិនាសដោយទំនងនេះ, សេចក្តីវិនាសនឹងគ្រប

សង្កត់សេចក្ដីចម្រើនដោយទំនងនេះ” ហើយក៏សម្រេចការចិញ្ចឹមជីវិតឲ្យសមគួរ តាមកម្លាំងទ្រព្យដែលបានដែលមានមិនបាយខ្ជះខ្ជាយពេក មិនរិះត្បិតត្បៀតពេក ។ ធម្មតាអ្នកកាន់ជញ្ជីង ឬកូនសិស្សអ្នកកាន់ជញ្ជីងកាលនឹងចាប់ជញ្ជីងយកមកកាន់ប្លឹងរមែងដឹងថាស្រាលប៉ុណ្ណោះធ្ងន់ប៉ុណ្ណោះ មានឧបមាដូចម្ដេចមិញ, ឧបមេយ្យ ដូចកុលបុត្រអ្នកប៉ិនប្រសប់រកស៊ីធ្វើការរមែងដឹងហេតុចម្រើន និងហេតុវិនាសរបស់ទ្រព្យសម្បត្តិ ក៏សម្រេចការចិញ្ចឹមជីវិតយ៉ាងល្មមសម មិនបាយវាយឲ្យជ្រុលដៃហួសប្រមាណ រហូតដល់ខ្វះមុខខ្វះក្រោយ ឬបំពាក់បំណុលគេច្រើនពេក, មិនរិះត្បិតត្បៀត រហូតដល់មិនហ៊ានស៊ីឆ្ងាញ់ មិនហ៊ានស្លៀកពាក់ល្អធ្វើដូចជាអ្នកក្រជ្រុលពេកនោះឡើយ ។ បើកុលបុត្រណារកស៊ីមិនចម្រើនតែបាយច្រើនហួសកុលបុត្រនោះលោកតិះដៀលថា ដូចអ្នកត្រូវការបរិភោគផ្លែល្វាយមួយផ្អែតតែកាប់ទាំងដើមទាំងមែកបេះយកផ្លែមកបរិភោគតែបន្តិចហើយបោល ផ្លែដែលសល់ខូចឥតអំពើ ។ បើកុលបុត្រណារកស៊ីចម្រើនច្រើន តែបាយតិចពេក,កុលបុត្រនេះលោកតិះដៀលថា

មានទ្រព្យស្តុកស្តម្ភស្លាប់ចោលទៅឥតអំពើ ។ ការបេះលៃលក បាយទ្រព្យចិញ្ចឹមជីវិត សមគួរនឹងកម្លាំងទ្រព្យដែលបានដែល-មានហៅថាសមជីវិតា(សភាពជាបុគ្គលចិញ្ចឹមជីវិតល្មមសម) ។ សមជីវិតានេះ មានអានុភាពដ៏សំខាន់ខាងឯធ្វើទ្រព្យសម្បត្តិ ដែលរកបានមកដោយឧដ្ឋានសម្បទាអារក្ខសម្បទានិងកល្យា-ណមិត្តតា ឲ្យបានសេចក្តីសុខស្រួលឲ្យមានរបៀបរៀបរយ ។

ព្រះពុទ្ធសាសនាប្រដៅអំពីការបាយទ្រព្យមាន ២ ន័យ, ន័យ ១ ឲ្យបែងចែកប្រាក់កាសជា ៤ ភាគ, ទុកសម្រាប់បរិភោគ ១ ភាគ, បំណាយជាដើមទុនប្រកបការរកស៊ី ២ ភាគ, ទុកឲ្យនៅទំនេរសម្រាប់ការពារអន្តរាយ ១ ភាគ, រួមជា ៤ ភាគ ។ ន័យ១ទៀត ឲ្យបែងចែកប្រាក់កាសជា ៤ ភាគដែរ តែក្នុងភាគមួយ ។ ស្មើគ្នា មិនឲ្យច្រើនម្ខាង ។ ហើយបាយក្នុងភាគទាំង ៤ នោះឲ្យបានផលប្រយោជន៍ទាំងជាតិនេះ និងជាតិខាងមុខ គឺ

១- ភាគ ១ ដោះបំណុលចាស់,

២- ភាគ ១ បុលយកបំណុលថ្មី,

៣- ភាគ ១ បោះក្នុងជ្រោះជ្រៅ,

## ៤-ភាគ ១ កប់ទុកជាកំណាប់ព្រេង ។

១- ត្រង់បទថា “បាយទ្រព្យភាគ ១ ដោះបំណុលចាស់” គឺបាយទ្រព្យសងគុណមាតាបិតាព្រោះមាតាបិតាជាមេបំណុល បុត្រធីតាជាកូនបំណុល, មាតាបិតាដែលបង្កើតបុត្រធីតាឲ្យកើតខ្លួនប្រាណមានជីវិត មានសាច់ឈាមជាដើមនោះ បានឈ្មោះថាបុលខ្លួនប្រាណ បុលជីវិត បុលសាច់ឈាមឲ្យកូន ឬដែលម្ដាយបំបៅដោះកូន ទំពាបាយបញ្ចុកកូន ឪពុកខំរកទ្រព្យចិញ្ចឹមកូន ក៏បានឈ្មោះថាបុលទឹកខ្សឹរ គឺទឹកដោះ បុលបាយទំពានិងបុលទ្រព្យសម្បត្តិឲ្យកូន, បំណែកខាងកូនក៏ឈ្មោះថាជាកូនបំណុលទឹកខ្សឹរ កូនបំណុលបាយទំពា និងកូនបំណុលទ្រព្យសម្បត្តិរបស់ម្ដាយឪពុក ។ ព្រោះហេតុនោះកូនប្រុសស្រីដែលជាអ្នកបំពាក់បំណុល ម្ដាយឪពុកជួបបានពោលមកហើយ មិនត្រូវបំភ្លេចគុណលោកទេ ត្រូវតែសងបំណុលលោកវិញ ទើបបានឈ្មោះថាជាមនុស្សកតញ្ញូកតវេទី ដឹងគុណលោក បានសម្ដែងគុណលោកឲ្យប្រាកដដល់ភ្នែកអ្នកផង គឺថាបើរកស៊ីបានទ្រព្យសម្បត្តិ ទោះច្រើនទោះតិច

ក៏ត្រូវតែបែងចែកប្រាក់កាសបំណែក ១ យកទៅបំណាយជាតម្លៃបច្ចុប្បច្ច័យគឺគ្រឿងស្លៀកពាក់, អាហារភោជន, គ្រឿងដេកអង្គុយ, ថ្នាំកែរោគ ជូនម្ដាយឪពុក ឬជូនប្រាក់កាសម្ដាយឪពុកឲ្យចាយតាមត្រូវការ ដើម្បីចិញ្ចឹមជីវិតម្ដាយឪពុកឲ្យស្រួលខ្លួនប្រាណ ឲ្យមានសាច់ឈាមមានជីវិតរស់នៅ ។ កូនណាបានធ្វើដូច្នេះជាដើម កូននោះឈ្មោះថា បានសងបំណុលខ្លួនប្រាណ បំណុលសាច់ឈាមដល់ម្ដាយឪពុកដែលជាបំណុលមានតាំងពីថ្ងៃបដិសន្ធិមកក្នុងលោក ជាបំណុលចាស់យូរណាស់ជាងបំណុលឯទៀត ដែលមានលើខ្លួន ។ ពាក្យអធិប្បាយនេះ ត្រូវតាមពុទ្ធដីកា ថា៖

**អយំ ខោ កាយោ រូបី ចាតុម្មហាភូតិកោ មាតា-បេតិកសម្ភវោ ឱទនកុម្មាសុបចយោ ។**

រូបកាយ (របស់បុត្រធីតា) ដែលមានមហាភូតរូបទាំង ៤ នេះ កើតឡើងអំពីមហាភូតរូបរបស់ម្ដាយឪពុក ចម្រើនឡើងដោយសារបាយទឹកនំចំណី ដែលម្ដាយឪពុកចិញ្ចឹម ។

ព្រោះហេតុនេះកាលបើបុត្រធីតាកើតឡើងមានវ័យចម្រើន

ហើយ ត្រូវគិតថា " អាត្មាអញជាមនុស្សដែលមាតាបិតាលោកចិញ្ចឹមមកហើយ អាត្មាអញត្រូវចិញ្ចឹមលោកវិញ "ដូច្នេះជាដើមឱ្យជានិច្ច កុំបីភ្លេចគុណលោកឡើយ ។ គំនិតដែលនឹករលឹកដល់ឧបការគុណរបស់មាតាបិតា ហៅថា"កតញ្ញូ ការដឹងឧប-ការគុណដែលលោកធ្វើហើយដល់ខ្លួន" កាលបើនឹករលឹកដល់គុណហើយបានសងគុណលោកវិញ បានឈ្មោះថា " កតញ្ញូកតវេទី ការដឹងគុណលោកហើយសម្ដែងគុណឱ្យប្រាកដ " ។ ការដែលកូនប្រុសស្រីចាយទ្រព្យភាគ ១ សងគុណម្ដាយឪពុកដូចរៀបរាប់មកនេះឈ្មោះថា ចាយទ្រព្យដោះបំណុលចាស់ ។

២- ត្រង់បទថា " ចាយទ្រព្យភាគ ១ បុលយកបំ-ណុលថ្មី " នោះ កាលបើជនជាម្ដាយឪពុកស្វែងរកប្រាក់កាសបានមកទោះបីតិចទោះបីច្រើន ត្រូវយកចំណែក១ចាយចិញ្ចឹមកូនប្រុសស្រី តាំងពីតូចរហូតដល់ធំ ឱ្យសមតាមកាលៈទេសៈ គឺសមតាមសម័យនិងប្រទេសដូចយ៉ាងពីក្មេងត្រូវចិញ្ចឹមដោយអាហារភោជន និងគ្រឿងស្លៀកពាក់ ដល់ធំបន្តិចឡើងល្មមពេលរៀនសូត្រ ត្រូវចាយប្រាក់ទំនុកបំរុងឱ្យរៀនសូត្រ គឺចាយ

ជាតម្លៃគ្រឿងសម្លៀកបំពាក់ឱ្យកូនស្មើមុខ នឹងកូនអ្នកដទៃ ព្រមទាំងចាយជាតម្លៃអាហារបំណើ យានជំនិះ និងប្រដាប់សម្រាប់រៀន មានសៀវភៅក្បួនច្បាប់ផ្សេង ៗ ជាដើម យកកូនទៅឱ្យរៀនក្នុងសាលារៀន អប់រំនិស្ស័យកូនឱ្យល្អឡើងជាលំដាប់ដរាបដល់បានសម្រេចបំណេះវិជ្ជា, វេលាដែលមានវ័យចម្រើនល្មមមានគូស្រករ ក៏ចាត់ចែងរៀបចំឱ្យមានស្វាមីភរិយា ហើយចែកប្រាក់កាសផ្ទះសម្បែងដីស្រែចម្ការ ឬទ្រព្យសម្បត្តិណា ៗ សមគួរតាមកម្លាំងដែលមាន ឱ្យជាដើមទុនសម្រាប់រកស៊ីជាដើម, យ៉ាងនេះ ហៅថា ចាយទ្រព្យបុលយកបំណុលថ្មី ។ បើម្ដាយឪពុកទំនុកបម្រុងកូនបែបនេះ រមែងបានផលយ៉ាងល្អ គឺបានទទួលការតបគុណអំពីកូនវិញ ។

៣- ត្រង់បទថា " យកទ្រព្យភាគ ១ ទៅបោះក្នុងជ្រោះជ្រៅ "នោះគឺចាយចិញ្ចឹមជីវិតខ្លួនឯង ៥ ផ្លូវ គឺផ្លូវភ្នែក ត្រចៀក ប្រមុះ អណ្ដាត កាយ ដោយប្រការផ្សេង ៗ, ភ្នែក ត្រចៀក ប្រមុះ អណ្ដាត កាយ ទាំង ៥ នេះ លោកទុកដូចជាជ្រោះឬរណ្ដៅ ព្រោះជារបស់ជ្រៅ កម្រនឹងបំពេញឱ្យពេញដោយ

រូប សំឡេង ក្លិន រស សម្ផស្សបាន, ការបាយវាយគ្រឿង សប្បាយក្នុងផ្លូវ ភ្នែក ត្រចៀក ប្រមុះ អណ្តាត កាយ យ៉ាងនេះ ហៅថា បោះក្នុងជ្រោះជ្រៅ, ឯភ្នែក ត្រចៀក ប្រមុះ អណ្តាត កាយនេះ បានជាហៅថាជ្រោះជ្រៅ ព្រោះភ្នែកមិនបេះ ឆ្អែតនឹងរូប ត្រចៀកមិនបេះឆ្អែតនឹងសំឡេង ប្រមុះមិនបេះឆ្អែតនឹងក្លិន អណ្តាតមិនបេះឆ្អែតនឹងរស កាយមិនបេះឆ្អែតនឹងសម្ផស្ស, បើពោលចំពោះអណ្តាត, អណ្តាតនេះ តែបរិភោគហើយមិនគង់នៅយូរប៉ុន្មានទេ, សេចក្តីនេះ សមដូចលោកពោលទុកក្នុងកាយវិរតិកថា ថា **“ឥតោ បក្ខិតមេតស្មឹ ឃត្តោ យាតិវ បូតិកំ** អាហារនុ៎ះដាក់ចូលទៅតាមផ្លូវនេះក៏ស្អុយរលួយហើយបេញទៅតាមផ្លូវនុ៎ះ” ដល់ទីបំផុតរាងកាយដែលប្រឹងបំប៉នដោយអាហារមកអស់កាលយូរ ក៏ដេកសង្កត់លើផែនដីមិនមានវិញ្ញាណ ដូចអង្កត់ឧស ឥតប្រយោជន៍ ។

៤- ត្រង់បទថា “យកទ្រព្យបំណែក ១ ទៅកប់ទុកជាកំណប់ព្រេង” នោះ គឺបាយធ្វើបុណ្យ ដូចយ៉ាងបរិច្ចាគបច្ច័យ ៤ គឺ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ បិញ្ជឹម

សមណៈព្រាហ្មណ៍ អ្នកប្រព្រឹត្តធម៌ត្រូវ ព្រមទាំងប្រកបការកុសលដទៃ ៗ ទៀត ដែលជាការទំនុកបម្រុងដល់មនុស្សជាតិឲ្យមានសេចក្ដីចម្រើនតាមអារ្យធម៌ ឬទំនុកបម្រុងពុទ្ធសាសនារហូតដល់ការកសាងទីកន្លែងបណ្ដុះសតិបញ្ញា មានសាលាបង្រៀនអក្សរ សាលាបង្រៀនបាលី មន្ទីរព្យាបាលរោគ វិថីផ្លូវថ្នល់ ស្ពាន កុដិ វិហារ វត្តអារាមជាដើម តាមសមគួរដល់កម្លាំងទ្រព្យដែលមានល្មមធ្វើបាន និងសមគួរដល់កាលៈទេសៈនោះៗ, ធ្វើដូច្នេះជាដើម ហៅថា ធ្វើបុណ្យ ។ បុណ្យនោះ បើបុគ្គលណាបានធ្វើហើយ ជាកំណាប់ទ្រព្យយ៉ាងប្រពៃក្រៃពេក ។ ពាក្យដែលពោលមកនេះ សមតាមព្រះពុទ្ធដីកាក្នុងនិធិកណ្ឌសូត្រ ថា៖

**ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ**
**បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ ។**

កំណាប់ទ្រព្យគឺបុណ្យនុ៎ះ ដែលបុគ្គលកប់ទុកល្អហើយ មិនមាននរណាផ្ចាញ់បាន នឹងជាប់តាមទៅ, កាលបុគ្គលលះបង់ភោគសម្បត្តិទាំងឡាយ គឺស្លាប់ទៅហើយ រមែងនាំយកកំណាប់នុ៎ះទៅបាន ។

ព្រោះហេតុនេះ បានជាលោកពោលថា ការដែលបុគ្គលយកទ្រព្យ ១ ចំណែកទៅចាយធ្វើបុណ្យនោះ បានឈ្មោះថាយកទៅកប់ទុកជាកំណាប់ព្រេង ។

ការបែកចាយទ្រព្យសម្បត្តិជា ៤ ចំណែកដូចពណ៌នាមកនេះហៅថា "សមជីវិតា ចិញ្ចឹមជីវិតសម ចិញ្ចឹមជីវិតស្មើ" ពាក្យថា សម ឬ ស្មើ ក្នុងទីនេះ សំដៅយកស្មើភាគគ្នា គឺដូចមានហិរញ្ញវត្ថុ ចំនួន ១០០ ត្រូវបែងទុកជា៤ភាគ, ភាគមួយ ៗ ២៥ រួមជា១០០, ភាគទី ១ សម្រាប់ដោះបំណុលចាស់ គឺសងគុណមាតាបិតា, ភាគទី ២ សម្រាប់បុលបំណុលថ្មី គឺចិញ្ចឹមបុត្តធីតា, ភាគទី ៣ សម្រាប់បោះក្នុងជ្រោះជ្រៅ គឺបរិភោគខ្លួនឯង, ភាគទី ៤ សម្រាប់កប់ទុកជាកំណាប់ព្រេង ពោលគឺធ្វើបុណ្យ, ទោះបីមានចំនួនតិចឬច្រើនជាងនោះ ក៏គប្បីវាយចំណែកជា ៤ តាមទំនងដូចពោលមកនេះ ទើបហៅថា ចិញ្ចឹមជីវិតសមតាមកម្លាំងទ្រព្យ ចិញ្ចឹមជីវិតស្មើ ។

និទានមានដំណាលប្រាប់រឿងចាយទ្រព្យ ថា៖

ក្នុងកាលកន្លងទៅយូរហើយ មានបុរសកំសត់ម្នាក់ ជា

មនុស្សបេះលៃលកបាយទ្រព្យត្រូវតាមគន្លងធម៌ ។ កាលដែលបិតាធ្វើមរណកាលទៅ បុរសនោះចិញ្ចឹមមាតាបាស់ព្រមទាំងកូនប្រពន្ធ ដោយការកាប់ឱសលក់ ។ វេលាមួយ បុរសនោះបររទេះគោចូលទៅរកឱសក្នុងព្រៃ បានឱសផ្ទុកពេញរទេះហើយ ក៏វែកឱសមួយអម្រែកដើរពីមុខរទេះ ត្រឡប់ទៅផ្ទះ ។ កាលបើបុរសនោះ កំពុងតែវែកឱសដើរមុខរទេះដូច្នោះ ព្រះរាជាទ្រង់ទតឃើញប្លែក ទ្រង់ត្រាស់ឲ្យហៅមកសួរថា "អ្នកឯង ម្ដេចក៏ប្លែកពីគេម្ល៉េះ តើយកឱសទៅធ្វើអ្វី?" ។ បុរសនោះក្រាបបង្គំទូលថា យកទៅលក់បានប្រាក់មកចែកជា៤ចំណែក គឺដោះបំណុលចាស់ ១, បុលបំណុលថ្មី ១, បោះក្នុងជ្រោះជ្រៅ ១, កប់ទុក ១ ។ ព្រះរាជាទ្រង់ឆ្ងល់ ក៏ត្រាស់សួរ, បុរសនោះក្រាបបង្គំទូលថា ដោះបំណុលចាស់ គឺចិញ្ចឹមម្ដាយ, បុលបំណុលថ្មី គឺចិញ្ចឹមកូន, បោះក្នុងជ្រោះជ្រៅ គឺទទួលព្រះរាជទានខ្លួនឯង, កប់ទុក គឺធ្វើទាន ។ ព្រះរាជាទ្រង់សោមនស្ស ក៏ប្រទានព្រះរាជទ្រព្យ ព្រមទាំងយសសក្តិ ឲ្យបានសេចក្ដីសុខសប្បាយតទៅ ។

ព្រះបោរាណាចារ្យនាំរឿងនេះមក ដើម្បីបង្ហាញឲ្យឃើញបែបផែន ក្នុងការចាយវាយទ្រព្យដែលសមតាមកម្លាំងទ្រព្យ ហើយត្រូវតាមគន្លងធម៌ផង ។

ការចេះលៃលកចាយទ្រព្យដូចពោលមកនេះ ហៅថា " សមជីវិតា ( សភាពជាបុគ្គលចិញ្ចឹមជីវិតស្មើ ) " ។ សមជីវិតានេះ ជាធម៌មានគុណានុភាពដ៏សំខាន់ខាងឯធ្វើទ្រព្យដែលរកបានមកដោយឧដ្ឋានសម្បទា, ចេះរក្សាដោយអារក្ខសម្បទា, មិនគប់រកពាលដោយកល្យាណមិត្តតានោះ ឲ្យសម្រេចប្រយោជន៍ដ៏ធំទូលាយ ។ ព្រោះហេតុនេះ បានជាព្រះដ៏មានបុណ្យជាបរមគ្រូទ្រង់លើកឡើងសម្ដែង ជាគម្រប់៤រងសម្បទា ៣ ខាងដើម ដើម្បីជាគ្រឿងទូទាត់បាត់បែងសម្បទាទាំង ៣ នោះឲ្យមានរបៀបរៀបរយល្អ ។

ធម៌ទាំង ៤ យ៉ាងគឺ ឧដ្ឋានសម្បទា អារក្ខសម្បទា សមជីវិតា និងកល្យាណមិត្តតានេះ ជាធម៌មានគុណានុភាពអាចញ៉ាំងជនជាគ្រហស្ថ ឲ្យតាំងខ្លួនជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ និងជាអ្នកមានរបៀបរៀបរយល្អ ដែលជាផលប្រយោជន៍

ឲ្យកើតសេចក្ដីសុខកាយសប្បាយចិត្ត យើញច្បាស់ទាន់ភ្នែកក្នុងបច្ចុប្បន្ន សមតាមសេចក្ដីប្រាថ្នា គួរជាទីសរសើររបស់អ្នកប្រាជ្ញទាំងឡាយ ។

ចប់ទិដ្ឋធម្មិកត្ថប្រយោជន៍ ។

# សម្បាយិកត្ថប្រយោជន៍

អធិប្បាយប្រយោជន៍ផ្លូវទៅខាងមុខ

ជនដែលត្រូវការសេចក្ដីសុខក្នុងលោកទាំងពីរ គឺលោកនេះនឹងលោកខាងមុខ កាលបើស្វែងរកប្រយោជន៍ក្នុងលោកនេះបានសមគួរដូចសេចក្ដីប្រាថ្នាហើយ, គួរស្វែងរកប្រយោជន៍ក្នុងលោកខាងមុខតទៅទៀត ។

ធម៌ដែលឲ្យសម្រេចប្រយោជន៍ក្នុងលោកខាងមុខមាន ៤ យ៉ាង គឺ

១- **សទ្ធាសម្បទា** ការបរិបូណ៌ដោយសទ្ធា,

២- **សីលសម្បទា** ការបរិបូណ៌ដោយសីល,

៣- **ចាគសម្បទា** ការបរិបូណ៌ដោយចាគៈ,

៤- **បញ្ញាសម្បទា** ការបរិបូណ៌ដោយបញ្ញា ។

១- **សទ្ធាសម្បទា** : កុលបុត្រជាអ្នកមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះតថាគតថា “ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង, ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ, ទ្រង់បរិបូណ៌

ដោយវិជ្ជានិងកិរិយាដែលគួរប្រព្រឹត្ត, ទ្រង់មានព្រះដំណើរល្អ យាងទៅកាន់ព្រះនិព្វាន, ទ្រង់ជ្រាបច្បាស់នូវត្រៃលោក, ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន, ទ្រង់ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន, ទ្រង់ជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច, ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត" , យ៉ាងនេះហៅថាអ្នកបរិបូណ៌ដោយសទ្ធា ។

**សទ្ធា** ប្រែថា សេចក្តីជឿ ជាឈ្មោះរបស់ចេតសិកមួយក្នុងចំណោមសោភនចេតសិក គឺចេតសិកដែលល្អៗ ជាប្រមុខនៃចេតសិកទាំងពួង ជាសហជាតធម៌កើតព្រមរលត់ព្រមជាមួយនឹងចិត្ត អាចដឹកនាំចិត្តឲ្យមានជំនឿក្នុងហេតុដែលគួរជឿផ្សេងៗ ។ ហេតុដែលគួរជឿនោះ លោកបែកចេញជា ៤ ប្រភេទ គឺ

១- **កម្មសទ្ធា** សេចក្តីជឿកម្ម,

២- **វិបាកសទ្ធា** សេចក្តីជឿផលរបស់កម្ម,

៣-**កម្មស្សកតាសទ្ធា** សេចក្តីជឿថាសត្វមានកម្ម ដែលខ្លួនធ្វើជារបស់ខ្លួន,

៤- **តថាគតពោធិសទ្ធា** សេចក្តីជឿញាណរបស់ព្រះតថាគត ។

ចេតនា សេចក្តីផ្តើមដំបូងបំផុតឈ្មោះថា "កម្ម", កាលបើកើតពីសេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេង ចាត់ជាអកុសលកម្ម, កើតពីសេចក្តីមិនលោភ សេចក្តីមិនក្រោធ សេចក្តីមិនវង្វេង ចាត់ជា "កុសលកម្ម" ។ ការដែលត្រិះរិះពិចារណាមើលឱ្យដឹងថា "បំណែកនេះជាកុសល បំណែកនេះជាអកុសល" ហើយជឿស៊ប់ថា "បំណែកនេះជាកម្មល្អ បំណែកនេះជាកម្មអាក្រក់" ដូច្នេះហៅថា កម្មសទ្ធា ។

សេចក្តីលំបាកកាយ លំបាកចិត្ត ដែលសត្វមិនប្រាថ្នា សត្វមិនគាប់ចិត្ត កើតឡើងអំពីផលរបស់បាបអកុសល ឬសេចក្តីសុខកាយសុខចិត្ត ដែលសត្វប្រាថ្នា សត្វគាប់ចិត្ត កើតឡើងអំពីផលរបស់បុណ្យកុសល ហៅថា "វិបាក ប្រែថា ផល" ការដែលត្រិះរិះពិចារណាមើលឱ្យដឹងច្បាស់នូវកម្ម

ជាហេតុ និងសុខទុក្ខជាផល ល្មមសមគួរដល់ហេតុនិងផល ហើយជឿស៊ប់ យ៉ាងនេះ ហៅថាវិបាកសទ្ធា ។

ពពួកសត្វសុទ្ធតែមានកម្ម គឺអំពើដែលខ្លួនធ្វើទាំងល្អទាំងអាក្រក់ជារបស់ជាប់តាមជានិច្ច ទាំងអស់គ្នា ជាអ្នកទទួលយកសុខនិងទុក្ខដែលជាផលរបស់បុណ្យនិងបាបនោះ ។ សេចក្ដីជឿថាសត្វមានអំពើដែលខ្លួនធ្វើទាំងល្អទាំងអាក្រក់ ជារបស់ខ្លួនៗ យ៉ាងនេះ ហៅថា កម្មស្សកតាសទ្ធា ។

សេចក្ដីជឿញាណ (ការត្រាស់ដឹង) របស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ថា ព្រះអង្គសម្បូរដោយព្រះគុណជាអនេកប្បការ មានព្រះវិសុទ្ធិគុណ ព្រះករុណាគុណ និងព្រះបញ្ញាគុណជាដើម ហៅថា តថាគតពោធិសទ្ធា ។

មានពុទ្ធភាសិតមួយកន្លែងសម្ដែងថា

ឧភោ បុញ្ញញ្ច ចាបញ្ច យំ មច្ចោ កុរុតេ ឥធ
តញ្ហិ តស្ស សកំ ហោតិ តញ្ច អាទាយ គច្ឆតិ
តញ្ចស្ស អនុគំ ហោតិ ឆាយាវ អនុបាយិនី ។

មនុស្សសត្វបានធ្វើកម្មឯណាទាំងពីរប្រការ ក្នុងលោកនេះ ទោះជាបុណ្យក្តី ជាបាបក្តី កម្មទាំងពីរប្រការនោះ ជារបស់គេ គេរមែងកាន់យកកម្មនោះទៅក្នុងលោកខាងមុខ កម្មនោះឯង រមែងជាប់ប្រកឹតតាមគេទៅ ដូចស្រមោលអន្ទោលតាមប្រាណ

**ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ**
**អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ**

សភាព ២ ប្រការ គឺកុសលធម៌ ១ អកុសលធម៌ ១ ឲ្យផលមិនស្មើគ្នា, អកុសលធម៌តែងនាំសត្វទៅនរក កុសលធម៌តែងនាំសត្វទៅស្ថានសួគ៌ ។

សម្តែងមកនេះ ដើម្បីបញ្ជាក់អំពីវិបាករបស់កម្មឲ្យច្បាស់លាស់ ។

ក្នុងព្រះសូត្រមានសម្តែងរឿង ១ ថា

កាលព្រះសម្មាសម្ពុទ្ធជាបរមគ្រូ គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី មានមាណពម្នាក់ឈ្មោះសុភមាណព ជាបុត្រតោទេយ្យព្រាហ្មណ៍ ចូលទៅក្រាបបង្គំទូលសួរព្រះអង្គ ថា

“បពិត្រព្រះគោតមដ៏ចម្រើន ! ហេតុបច្ច័យដូចម្តេច ដែលនាំឲ្យមនុស្សថោកទាបនិងខ្ពង់ខ្ពស់ខុសគ្នា គឺមនុស្សពួកខ្លះមានអាយុខ្លី ពួកខ្លះមានអាយុវែង, ពួកខ្លះមានរោគតិច ពួកខ្លះមានរោគច្រើន, ពួកខ្លះមានរូបអាក្រក់ ពួកខ្លះមានរូបល្អ ពួកខ្លះឥតយសស័ក្តិ ពួកខ្លះមានយសស័ក្តិ, ពួកខ្លះមានភោគសម្បត្តិតិច ពួកខ្លះមានភោគសម្បត្តិច្រើន, ពួកខ្លះមានត្រកូលទាប ពួកខ្លះមានត្រកូលខ្ពស់, ពួកខ្លះមានប្រាជ្ញាតិច ពួកខ្លះមានប្រាជ្ញាច្រើន ។

ព្រះអង្គត្រាស់ថា “ម្នាលមាណព ! សត្វទាំងឡាយមានកម្មជាបុណ្យជាបាបដែលធ្វើហើយជារបស់ខ្លួនជាមត៌កជាកំណើតជាផៅពង្ស ជាគ្រឿងរឭក, ព្រោះកម្មនោះជាអ្នកបាត់បែងចែករំលែកសេចក្តីអាក្រក់ល្អឲ្យពួកសត្វតាមសមគួរ ដល់ចេតនាដែលសត្វផ្តើមធ្វើបានជាពួកសត្វមានសភាពជាសត្វថោកទាបនិងខ្ពង់ខ្ពស់ខុសគ្នាគឺ បុគ្គលណាសម្លាប់គេ បុគ្គលនោះរមែងធ្លាក់ទៅកើតក្នុងអបាយ គឺ តិរច្ឆាន ប្រេត អសុរកាយ នរក,បើមិនដូច្នោះរមែងកើតជាមនុស្សអាយុខ្លី, បុគ្គលណាវៀរចាកការ

សម្លាប់គេ បុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក, បើមិនដូច្នោះ រមែងកើតជាមនុស្សអាយុវែង, បុគ្គលណាបៀតបៀនគេដោយដំបងព្រនង់ ឬ ដោយគ្រឿងសស្ត្រាវុធផ្សេងៗ បុគ្គលនោះរមែងទៅកើតក្នុងអបាយ បើមិនដូច្នោះ រមែងកើតជាមនុស្សមានជំងឺតម្កាត់ច្រើន, បុគ្គលណាមិនបៀតបៀនគេ បុគ្គលនោះ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក, បើមិនដូច្នោះរមែងកើតជាមនុស្សមានជំងឺតម្កាត់តិច, បុគ្គលណាមានកំហឹងច្រើនចងគំនុំ បុគ្គលនោះរមែងទៅកើតក្នុងអបាយ, បើមិនដូច្នោះ រមែងកើតជាមនុស្សមានរូបអាក្រក់, បុគ្គលណាមិនមានកំហឹង មិនចងគំនុំ បុគ្គលនោះ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក, បើមិនដូច្នោះរមែងកើតជាមនុស្សមានរូបល្អ, បុគ្គលណាមានចិត្តឈ្នានីសគេបុគ្គលនោះរមែងទៅកើតក្នុងអបាយ បើមិនដូច្នោះរមែងកើតជាមនុស្សឥតយសស័ក្តិបរិវារ, បុគ្គលណាមិនមានចិត្តឈ្នានីសគេបុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក, បើមិនដូច្នោះ រមែងកើតជាមនុស្សមានយសស័ក្តិបរិវារច្រើន, បុគ្គលណាមានសេចក្តីកំណាញ់ មិនឲ្យទាន

បុគ្គលនោះរមែងទៅកើតក្នុងអបាយ, បើមិនដូច្នោះរមែងកើតជាមនុស្សមានភោគសម្បត្តិតិច, បុគ្គលណាលះសេចក្តីកំ-ណាញ់ ឲ្យទាន បុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវ-លោក,បើមិនដូច្នោះរមែងកើតជាមនុស្សមានភោគសម្បត្តិច្រើន បុគ្គលណារឹងរូឹង មើលងាយគេ បុគ្គលនោះរមែងទៅកើតក្នុងអបាយ, បើមិនដូច្នោះរមែងកើតជាមនុស្សត្រកូលទាប, បុគ្គលណាមិនរឹងរូឹង មិនមើលងាយគេ បុគ្គលនោះរមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក, បើមិនដូច្នោះ រមែងកើតជាមនុស្សមានត្រកូលខ្ពស់, បុគ្គលណាមិនឧស្សាហ៍សាកសួរអ្នកប្រាជ្ញ មិនរៀនសូត្របុគ្គលនោះរមែងទៅកើតក្នុងអបាយ បើមិនដូច្នោះរមែងជាមនុស្សអប្បប្រាជ្ញា, បុគ្គលណាឧស្សាហ៍សាកសួរអ្នកប្រាជ្ញបានរៀនសូត្រ បុគ្គលនោះ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក,បើមិនដូច្នោះ រមែងកើតជាមនុស្សមានប្រាជ្ញាច្រើន

សេចក្តីជឿតាមន័យក្នុងព្រះសូត្រនេះ ហៅថា កម្មសទ្ធា វិបាកសទ្ធា និងកម្មស្សកតាសទ្ធា ។

បណ្តាសទ្ធាទាំង ៤ យ៉ាង គឺ កម្មសទ្ធា វិបាកសទ្ធា

កម្មស្សកតាសទ្ធា តថាគតពោធិសទ្ធា នោះ មានតថាគតពោ-ធិសទ្ធា ប្រសើរជាងសទ្ធាទាំង ៣ ព្រោះសទ្ធាទាំង ៣ នោះ មានទាំងក្នុងពុទ្ធកាល ទាំងក្រៅពុទ្ធកាល, ឯតថាគតពោធិ-សទ្ធា មានចំពោះតែក្នុងពុទ្ធកាល គឺកាលដែលព្រះពុទ្ធជាម្ចាស់យាងមកត្រាស់ក្នុងលោកម្តងៗប៉ុណ្ណោះ ។ អធិប្បាយថា កាលព្រះសម្មាសម្ពុទ្ធ មិនទាន់យាងមកត្រាស់ក្នុងលោកនេះ សាស្តាជាកម្មវាទី ក៏ប្រដៅប្រជាជនប្រកបដោយហេតុផល ឲ្យឃើញតាម ឲ្យកាន់តាមដែរ, តែឲ្យអ្នកដែលប្រព្រឹត្តតាមនោះបានត្រឹមតែឋានមនុស្ស-ទេវតា និងព្រហ្មលោកប៉ុណ្ណោះ, លុះព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក ទើបទ្រង់សម្តែងប្រដៅវេនេយ្យសត្វដែលប្រតិបត្តិតាមពុទ្ធោវាទ ឲ្យបានសម្រេចមគ្គផលព្រះនិព្វាន រួចចាកសង្សារទុក្ខវិសេសជាងនោះថែមឡើងទៀត ។ ព្រោះហេតុនេះការជឿចំពោះសេចក្តីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ទើបប្រសើរជាងការជឿទាំងពួង ។

សទ្ធា បើពោលឲ្យខ្លីមានតែ ២ យ៉ាង គឺ

១- **លោកិយសទ្ធា** ការជឿជាប់នៅក្នុងលោក,

២- លោកុត្តរសទ្ធា ការជឿធ្លងផុតបាកលោក ។

ចាប់ដើមអំពីសាធុជនជឿថា ព្រះពុទ្ធមានព្រះគុណច្រើនប្រការ មានព្រះអរហំសម្មាសម្ពុទ្ធោជាដើម មាំមួនហើយមានសេចក្ដីស្រឡាញ់ចំពោះព្រះពុទ្ធគុណនោះៗ ព្យាយាមស្ដាប់ព្រះធម៌ដែលជាពុទ្ធឱវាទរបស់ព្រះអង្គ ហើយពិចារណាជ្រើសរើសរកធម៌ទាំងជាកុសលទាំងជាអកុសល, ត្រង់ណាជាអកុសលក៏លះបង់ ត្រង់ណាជាកុសលក៏ប្រតិបត្តិតាម, បើសោតាបត្តិមគ្គលោកុត្តរកុសល នៅមិនទាន់កើតឡើងដរាបណា, ការជឿដែលប្រព្រឹត្តទៅក្នុងកាលដរាបនោះជាលោកិយសទ្ធា ។ ចាប់ដើមអំពីសោតាបត្តិមគ្គញាណកើតឡើងទៅ ជាលោកុត្តរសទ្ធា ។

លក្ខណៈគ្រឿងសម្គាល់របស់អ្នកមានសទ្ធា មាន ៣ យ៉ាង គឺ

១- ចង់ជួបនឹងសប្បុរសអ្នកមានសីល,

២- ចង់ស្ដាប់ធម៌របស់សប្បុរស,

៣-លះបង់សេចក្ដីកំណាញ់ជាមន្ទិល ។

សឹងមានពុទ្ធភាសិតគាថាជាសំអាងថា :

**ទស្សនកាមោ សីលវតំ សទ្ធម្មំ សោតុមិច្ឆតិ**
**វិនេយ្យមច្ឆេរមលំ ស វេ សទ្ធោតិ វុច្ចតិ ។**

បុគ្គលណាចង់ឃើញពួកបុគ្គលអ្នកមានសីល ចង់ស្តាប់ធម៌របស់សប្បុរស កម្ចាត់បង់សេចក្តីកំណាញ់ជាមន្ទិលចេញបាន បុគ្គលនោះ ហៅថា អ្នកមានសទ្ធា ។

មានពុទ្ធភាសិតសរសើរសទ្ធា ថា :

**សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ**
**ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**សច្ចំ ហវេ សាធុតរំ រសានំ**
**បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ ។**

សទ្ធា ជាទ្រព្យប្រសើរខ្ពង់ខ្ពស់របស់បុរស ក្នុងលោកនេះ, ធម៌ដែលបុគ្គលសន្សំហើយ តែងនាំសេចក្តីសុខមកឲ្យ, ពាក្យសច្ចៈមានរសឆ្ងាញ់ក្រៃលែងជាងរសទាំងឡាយ, ជនដែលរស់នៅដោយមានប្រាជ្ញា ហៅថា អ្នករស់នៅប្រសើរ ។

ធម្មតាទ្រព្យសម្បត្តិ ទោះជាទ្រព្យមានវិញ្ញាណក្តី ទ្រព្យឥតវិញ្ញាណក្តីរមែងឲ្យកើតសេចក្តីពេញចិត្តដល់ម្ចាស់របស់ចំពោះតែក្នុងលោកនេះប៉ុណ្ណោះ, កាលម្ចាស់របស់ស្លាប់ហើយយកទៅបរលោកផងមិនបាន, បុគ្គលដែលមានចិត្តជាអកុសលធ្វើតែអំពើបាប ឥតធ្វើអំពើបុណ្យសោះ ទោះបីមានទ្រព្យសម្បត្តិច្រើនយ៉ាងណា វេលាទៀបលះលោកនេះ ទៅកាន់លោកខាងមុខ ខ្លាចក្រែងទៅកើតក្នុងអបាយ ក៏យកទ្រព្យអំបាលនោះទៅសូកប៉ាន់ ឬទិញដូរសម្បត្តិមនុស្ស សម្បត្តិសួគ៌ដែលជាសម្បត្តិក្នុងលោកខាងមុខ ឲ្យតែបានមកកើតជាមនុស្សវិញ ឬទៅកើតក្នុងឋានសួគ៌ក៏ពុំបានឡើយ, លុះតែមានសទ្ធាជាដើមទុនហើយចាយទ្រព្យទាំងនោះធ្វើបុណ្យទាន ទើបអាចដូរយកសម្បត្តិទាំង ៣ គឺ សម្បត្តិមនុស្ស សម្បត្តិសួគ៌ សម្បត្តិនិព្វាន ក្នុងលោកខាងមុខបាន ។

ការបរិបូណ៌ដោយសេចក្តីជឿតាមន័យដូចពោលមកនេះជាដើម ហៅថា សទ្ធាសម្បទា ។

សទ្ធា ជាចេតសិកមួយ ក្នុងពួកសោភនចេតសិកជាធម្មជាតនាំមុខចេតសិកទាំងពួងឲ្យជឿស៊ប់ក្នុងការកុសល ។

ព្រោះហេតុនេះបានជាព្រះអរហន្តសម្មាសម្ពុទ្ធជាបរមគ្រូកាលទ្រង់សម្តែងអំពីធម៌ដែលនាំឲ្យសម្រេចប្រយោជន៍ជូនទៅខាងមុខ គឺប្រយោជន៍ក្នុងបរលោក ទើបទ្រង់លើកយកសទ្ធាឡើងសម្តែងជាខាងដើម ជាប្រធាននៃសម្បទាទាំងពួង ។

២- **សីលសម្បទា** កុលបុត្រក្នុងលោកនេះវៀរបាកការសម្លាប់សត្វ វៀរបាកការលួចទ្រព្យដែលគេមិនបានឲ្យដោយកាយឬវាចា វៀរបាកការប្រព្រឹត្តខុសក្នុងកាម វៀរបាកការនិយាយកុហក វៀរបាកការផឹកទឹកស្រវឹងគឺសុរានិងមេរ័យជាទីតាំងនៃសេចក្តីប្រមាទ យ៉ាងនេះហៅថា សីលសម្បទា ។

**សីល** ប្រែថា ប្រក្រតី សម្គាល់សេចក្តីថា ការរក្សាកាយវាចាឲ្យរៀបរយជាប្រក្រតី ប្រាសចាកទោសដែលជាបាបគួរគិះដៀលតាំងពីប្រព្រឹត្តកាយវាចាឲ្យមានកិរិយាមារយាទទន់ភ្លន់សុភាពរាបសារល្អ មិនបៀតបៀនអ្នកដទៃឲ្យបានសេចក្តីក្តៅក្រហាយជាដើម, នេះឯង ជាលក្ខណៈរបស់សីល ។

សីល កាលបើនិយាយដោយឆ្ងាយទូលាយទូទៅ បែកជា ២ គឺ សីលរបស់គ្រហស្ថ មានឈ្មោះថា អាគារិយវិន័យ ១, សីលរបស់បព្វជិត មានឈ្មោះថា អនាគារិយវិន័យ ១, ក្នុងពួកសីលរបស់គ្រហស្ថបែកជា ២ គឺ សីល ៥ ឬនិច្ចសីល ១ សីល ៨ ឬឧបោសថសីល១, ក្នុងពួកសីលរបស់បព្វជិតបែកជា ២ គឺ បតុប្បារិសុទ្ធិសីល បានខាងសីលរបស់ភិក្ខុ ១, សីល១០ បានខាងសីលរបស់សាមណេរ១ ។

និច្ចសីល និងឧបោសថសីល មានលក្ខណៈប្លែកគ្នាដោយព្រះបញ្ញត្តិ គឺ និច្ចសីល ទ្រង់បញ្ញត្តឡើងដោយបម្រុងនឹងឲ្យមនុស្សទូទៅរក្សាបានគ្រប់គ្នាទាំងអស់ និងឲ្យរក្សាបានជានិច្ចឲ្យនៅជាសុខគ្រប់គ្នាដោយសេចក្ដីមិនមានភ័យ មិនមានពៀរនឹងគ្នា, ដោយហោចទៅសូម្បីសត្វតិរច្ឆានក៏គួរទទួលយកព្រះបញ្ញត្តិនេះទៅរក្សាបានដែរ, បំណែកឧបោសថសីល ទ្រង់បញ្ញត្តិឡើងដោយបម្រុងនឹងឲ្យជាព្រហ្មចរិយៈ គឺការប្រព្រឹត្តដ៏ប្រសើររបស់គ្រហស្ថ ដើម្បីវៀរចាកកិច្ចការខ្លះដែលនាំឲ្យសៅហ្មងចិត្ត ជាការប្រតិបត្តិដ៏ប្រសើរជាងនិច្ចសីល ជាគ្រឿង

អប់រំនិស្ស័យនិងមារយាទឲ្យល្អវិសេសឡើង ទាក់ទងដោយការរក្សាសច្ចៈ (សេចក្ដីពិត) ដែលគ្រហស្ថគួរធ្វើបាន មានកំណត់ត្រឹមថ្ងៃ ១ យប់១ ជាសីលដែលគ្រហស្ថគប្បីរក្សាក្នុងកាលវិសេស គឺថ្ងៃ៥កើត ៥រោច, ៨កើត ៨រោច ១៤កើត ១៤រោច, ១៥កើត ១៥រោច ។

សីល ជាគុណសម្បត្តិយ៉ាងសំខាន់ អាចកម្ចាត់ភ័យមានអត្តានុវាទភ័យ គឺខ្លួនឯងក៏តិះដៀលខ្លួនឯងមិនបាន,កាលបើខ្លួនឯងតិះដៀលខ្លួនឯងមិនបានហើយ អ្នកដទៃណាគេនឹងត្មះតិះដៀលបាន, ព្រោះហេតុនោះ ទើបឈ្មោះថា ឲ្យអភ័យដល់មនុស្សទូទៅ នឹងឲ្យកើតសេចក្ដីល្អស្មើរតែគ្រប់យ៉ាង ។

សីល ជារបស់ល្អគូនឹងជីវិត, ជីវិតអ្នកមានសីល ជាជីវិតមានខ្លឹមសារ, ជីវិតអ្នកឥតសីល ជាជីវិតឥតប្រយោជន៍ ។

លោកសម្ដែងអានិសង្សថា

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

ជនទាំងឡាយ បានទៅកាន់ឋានសួគ៌ព្រោះសីល, ជន

ទាំងឡាយបានភោគសម្ប័ទព្រោះសីល, ជនទាំងឡាយបានទៅកាន់ឋានព្រះនិព្វានព្រោះសីល, ព្រោះហេតុនោះ បុគ្គលគប្បីសម្អាតសីលឲ្យស្អាតល្អ ។

ព្រោះហេតុសីលមានអានិសង្សដូចពោលមកនេះ បានជាព្រះសក្យមុនីជាបរមគ្រូ កាលនឹងទ្រង់សម្ដែងអំពីធម៌ដែលនាំឲ្យសម្រេចប្រយោជន៍ដ៏ទៅខាងមុខ គឺប្រយោជន៍ក្នុងបរលោកទើបទ្រង់លើកសីលឡើងសម្ដែងជាសម្បទាទី ២ រងអំពី សទ្ធាសម្បទា មក ។

៣- **ចាគសម្បទា** កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ស្វិត នៅគ្រប់គ្រងផ្ទះមានចាគៈរួចហើយ មានដៃលាងហើយបម្រុងចាំតែបរិច្ចាគទាន ត្រេកអរក្នុងការលះ គួរដល់ការសូម ត្រេកអរក្នុងការឲ្យនិងការចែករំលែក, យ៉ាងនេះ ហៅថា ចាគៈ ។

ចាគៈ ប្រែថា ការលះ, លោកចែកជា ២ យ៉ាង គឺ

១- អាមិសចាគៈ ការលះវត្ថុមានបាយទឹកជាដើមឲ្យដល់អ្នកដទៃ,

២- ធម្មបាគៈ ការលះធម៌បែកធម៌ឲ្យដល់អ្នកដទៃ ។

វត្ថុទាំងឡាយមានសំពត់បាយទឹកជាដើមហៅថាអាមិស ព្រោះជាគ្រឿងលល្ងងចិត្តសត្វឲ្យវិលវល់ស្លាប់កើត នៅក្នុងវដ្តសង្សារ, ការលះបង់អាមិស ដល់បុគ្គលដែលគួរលះ ហៅថា អាមិសបាគៈ ។

សេចក្តីល្អ សេចក្តីប្រពៃ ជាសភាពដែលសត្វគួរប្រព្រឹត្ត ដោយត្រៃទ្វារ ហៅថា ធម៌ ។ ធម៌នោះ លោកបែកជា ៣ បំណែកគឺ បរិយត្តិធម៌ បដិបត្តិធម៌ បដិវេធធម៌, ព្រះវាចាដែលព្រះសម្មាសម្ពុទ្ធត្រាស់ទេសនាប្រៀនប្រដៅវេនេយ្យសត្វ ឬបន្លឺជាឧទាន នឹងតែងតែជាសិក្ខាបទពុទ្ធអាជ្ញាដែលមានក្នុងព្រះត្រៃបិដកទាំងមូល ហៅថា បរិយត្តិធម៌ ជាធម៌សម្រាប់កុលបុត្តពុទ្ធសាសនិករៀនសូត្រឲ្យបេះដឹង, បរិយត្តិធម៌នោះឯង សម្តែងសេចក្តីប្រតិបត្តិ គឺ សីល សមាធិ បញ្ញា ឯណា, សីល សមាធិ បញ្ញានោះ ឈ្មោះថា បដិបត្តិធម៌, កាលបើកុលបុត្រ បានប្រតិបត្តិតាមសីល សមាធិ បញ្ញានោះហើយបានសម្រេច

អរិយមគ្គ អរិយផល ព្រះនិព្វានឯណា, អរិយមគ្គ អរិយផល ព្រះនិព្វាននោះ ឈ្មោះថា បដិវេធធម៌ ។

បណ្ដាធម៌ទាំង៣យ៉ាងនេះ, បុគ្គលបានសម្រេចធម៌ណាមួយដោយច្បាស់លាស់ ហើយចែករំលែកធម៌នោះ គឺសម្ដែងឲ្យអ្នកដទៃស្ដាប់ ឬរៀបរៀងតែងទុកជាច្បាប់ឲ្យអ្នកដទៃរៀនសូត្រតាម ដើម្បីគេបានឮបានស្ដាប់ហើយគេតាំងខ្លួននៅក្នុងធម៌ទាំង ៣ យ៉ាងនេះ តាមគួរដល់ឧបនិស្ស័យវាសនា, យ៉ាងនេះ ហៅថា ធម្មចាគៈ ។

បណ្ដាចាគៈទាំង២នេះ, ធម្មចាគៈ (ការលះធម៌) ប្រសើរជាងអាមិសចាគៈ (ការលះអាមិស) ។

បុគ្គលប្រកបដោយការលះទាំង ២ យ៉ាងនេះ យ៉ាងណាមួយ ឈ្មោះថា បរិបូណ៌ដោយចាគសម្បទា ។

មានពុទ្ធភាសិតបណ្ដុះបិត្តពុទ្ធបរិស័ទឲ្យកើតចាគៈ ថា៖

**មត្តា សុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ**
**ចជេ មត្តា សុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។**

បើបុគ្គលឃើញសុខដ៏ធំទូលាយ គប្បីលះសុខល្មម

ប្រមាណ, អ្នកប្រាជ្ញឃើញសុខដ៏ធំទូលាយ គប្បីលះសុខល្មមប្រមាណ ។

សេចក្ដីសប្បាយ ដែលកើតព្រោះមានទ្រព្យ មានយស និងមានមេត្រីអំពីមនុស្សទាំងឡាយ ដែលឯកជនគប្បីបាន គប្បីដល់ ឈ្មោះថា សុខល្មមប្រមាណ គឺសុខយ៉ាងតូច, សុខរបស់មនុស្សម្នាក់ បើធៀបនឹងសុខរបស់មនុស្សច្រើននាក់ ឃើញថា ជាសុខបន្តិចបន្តួចណាស់ ព្រោះមនុស្សម្នាក់នឹងនៅបានយូរប៉ុន្មាន មិនយូរក៏នឹងស្លាប់, ទ្រព្យក្ដី យសក្ដី មេត្រីក្ដី ដែលបុគ្គលម្នាក់ខំខ្វល់ខ្វាយរកបានមកនោះ រមែងសម្រេចប្រយោជន៍បានតែមួយជីវិតប៉ុណ្ណោះ, លុះស្លាប់ហើយក៏ឥតប្រយោជន៍តទៅ, ព្រោះហេតុនោះ សេចក្ដីសុខក្ដី វត្ថុជាទីតាំងនៃសេចក្ដីសុខក្ដី ដែលឯកជនត្រូវបាន ទើបឈ្មោះថា ជាសុខយ៉ាងតូច ។ សុខដែលមនុស្សទាំងឡាយ គឺ មាតា បិតា បុត្រភរិយា រហូតដល់វង្សញាតិក្នុងត្រកូលមួយ ៗ ត្រូវបានសព្វគ្នា បើធៀបនឹងសុខរបស់ជនក្នុងពួកនោះ ឈ្មោះថា សុខដ៏ធំទូលាយគ្រាន់បើ ព្រោះសុខច្រើនគ្នា, ប៉ុន្តែសុខបំពោះ

ត្រកូលមួយៗ បើធៀបនឹងសុខរបស់មនុស្សរួមជាតិក៏នៅតែឈ្មោះថា ជាសុខយ៉ាងតូចនៅឡើយ, សុខដែលពួកមនុស្សរួមជាតិទាំងមូលត្រូវបាននោះឯង ជាសុខយ៉ាងធំទូលាយជាងព្រោះជាសាធារណសុខសព្វគ្នាទូទៅ ។ សុខរបស់មនុស្សទូទៅទាំងផ្ទៃលោក ជាសុខដ៏ធំទូលាយបំផុត ដែលមនុស្សសាមញ្ញរកមិនងាយបាន ។ ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ប្រទានព្រះបរមពុទ្ធោវាទទុកក្នុងទីនេះ ដើម្បីបញ្ជាក់អំពីសេចក្តីសុខដែលមនុស្សច្រើនគ្នាត្រូវបាន ថាជាសុខយ៉ាងសំខាន់ជាង ដោយទ្រង់មានព្រះបំណងនឹងឲ្យពុទ្ធសាសនិកលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ព្យាយាមធ្វើប្រយោជន៍ដល់មនុស្សច្រើន ។ ន័យមួយទៀតបើសម្លឹងដល់ជីវិតបំពោះបុគ្គលម្នាក់ក៏ជារបស់ខ្លីរបស់តូច មិនឋិតថេរបានយូរប៉ុន្មាន, សម្លឹងដល់សេចក្តីតាំងនៅនៃត្រកូល ទើបឃើញថាយូរជាង, សេចក្តីតាំងនៅនៃជាតិ អាចឋិតថេរបានយូរជាងសេចក្តីតាំងនៅនៃត្រកូល, កាលត្រកូលក្តី ជាតិក្តី តាំងនៅបានត្រឹមណា, ខ្លួនក៏ឈ្មោះថា

តាំងនៅបានត្រឹមនោះ ព្រោះមានសែស្រឡាយសល់នៅ, ហេតុនេះ បុគ្គលគួរឃើញប្រយោជន៍បំណែកមនុស្សច្រើនថាធំជាងប្រយោជន៍បំណែកខ្លួន, បើប្រសិនជាអាចលះបង់ប្រយោជន៍បំណែកខ្លួន ដើម្បីឲ្យសម្រេចប្រយោជន៍ដល់មនុស្សច្រើនបាន ក៏គួរ ។

ឧបាយដែលលះសុខយ៉ាងតូច ដោយប៉ងយកសុខដ៏ធំទូលាយគឺផ្លូវដែលស៊ូលះសុខបំណែកខ្លួនដើម្បីសុខដល់មនុស្សច្រើននោះ បានដល់ការលះទ្រព្យរបស់ខ្លួនទំនុកបម្រុងដល់មនុស្សទាំងឡាយ ដោយអធ្យាស្រ័យប្រកបដោយមេត្តាករុណាទោះបីពួកមនុស្សអំបាលនោះឥតមានទាក់ទងដោយហេតុណាមួយដែលខ្លួនត្រូវអនុគ្រោះសោះក៏អាចសង្គ្រោះបាន ។ រឿងនេះគប្បីឃើញក្នុងទក្ខិណាទានរបស់គហបតី ដែលបរិច្ចាគដល់បព្វជិត ឲ្យទានដល់មនុស្សអនាថា មនុស្សជរា មនុស្សពិការ ។ ព្រះបោរាណាចារ្យនិទានរឿងសេដ្ឋីចិត្តសប្បុរស មានអនាថ-បិណ្ឌិកសេដ្ឋីជាដើម ដែលតាំងរោងទានចែកអាហារដល់មនុស្សកំសត់ ក៏ដើម្បីសម្ដែងសេចក្ដីនេះ, តែអ្នកបរិច្ចាគ អ្នកឲ្យ

ទាននោះ គួរប៉ុនប៉ងឲ្យជាផលពិតៗដល់បដិគ្គាហកៈអ្នកទទួលផង ទើបបាត់ជាសប្បុរិសទាន គឺការឲ្យរបស់សប្បុរស បើបេះតែឲ្យៗទៅនឹងជាប្រយោជន៍ឬជាទោសដល់អ្នកទទួលក៏តតដឹងមិនបាត់ជាសប្បុរិសទានទេ ។ ព្រះបោរាណាចារ្យសម្តែងការឲ្យបំពួកខ្លះ ដូចការឲ្យទឹកស្រវឹង ឲ្យល្បែងជាការលេងនាំឲ្យកើតកិលេសជាដើម ថាមិនបាត់ជាទាន ក៏ដើម្បីបង្ហាញសេចក្តីនេះឯង ។ ទានវត្ថុឲ្យហើយជាការមានប្រយោជន៍ដល់អ្នកទទួលក៏មាន ជាទោសដល់អ្នកទទួលក៏មាន គប្បីឃើញដូចមនុស្សជរាពិការដែលមិនអាចចិញ្ចឹមជីវិតដោយខ្លួនឯងបានកាលទទួលទានដែលអ្នកដទៃឲ្យហើយ រមែងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានដោយមិនអត់ឃ្លាន, បំណែកមនុស្សដែលមានកម្លាំងអាចធ្វើការងារបាន តែជាមនុស្សមិនមានខ្មាស កាលបានទទួលទានអ្នកដទៃ ហើយត្រឡប់ជាត្រេកអរឃើញថាសុំគេបានងាយៗមិនបាច់ធ្វើការឲ្យហត់នឿយ, ឲ្យទានដល់មនុស្សបែបនេះ មិនអាចជួយគេឲ្យរួចចាកសេចក្តីអត់ឃ្លានបានឡើយត្រឡប់ជាធ្វើគេឲ្យលិចបុះក្នុងរណ្តៅនោះវិញ ។ ក្នុងព្រះសូត្រ

ពោលដល់រឿងវេលាមព្រាហ្មណ៍ឲ្យទានយ៉ាងច្រើនដល់មនុស្ស សាម័ញ្ញ កម្រអ្នកណាធ្វើបាន, តែមានដំណឹងថាមិនបាន ផលបរិបូណ៌ស្មើនឹងប្រគេនព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដែលជាបុគ្គលញ៉ាំងលោកឲ្យរុងរឿងនោះឡើយ, ទាំងនេះ ក៏ដោយហេតុវេលានោះមិនមានត្រៃសរណគមន៍និងអ្នកឲ្យមិន សម្លឹងឃើញផលដែលត្រូវមានដល់បដិគ្គាហកៈនោះឯង ។

ការឲ្យទានដល់បុគ្គល មានល្អ មានខូច ដូចពោលមក នេះ ។ ព្រះបរមសាស្ដាទ្រង់សរសើរការឲ្យទានដល់បុគ្គលអ្នក បានធ្វើល្អដល់ខ្លួននិងអ្នកដទៃ និងការឲ្យទានជាសាធារណៈ ថាជាទានដ៏ប្រសើរ, ឯការឲ្យទានដល់បុគ្គលអ្នកបានធ្វើល្អ នោះទ្រង់សម្ដែងការកសាង ការបដិសង្ខរណៈគឺការជួសជុល វត្តអារាម សាលា កុដិ ជាសង្ឃទានប្រគេនព្រះសង្ឃអ្នកប្រកប កិច្ចព្រះពុទ្ធសាសនា, ឯការឲ្យទានជាសាធារណៈនោះ ទ្រង់ សម្ដែងការដាំដើមឈើទុកជាទីសំណាក់អាស្រ័យ ជាម្លប់ សាងថ្នល់ ផ្លូវ ស្ពាន សាលាសំណាក់ ជីកអណ្ដូងទឹក តាំង រានទឹកជាទាន, សាងសាលារៀន និងទំនុកបម្រុងការរៀនសូត្រ

សាងមន្ទីរពេទ្យ និងទំនុកបម្រុងការព្យាបាលរោគ ក៏ចាត់ជាសប្បុរិសទាន, ព្រោះក្មេងៗដែលរៀនសូត្រ កាលបានទទួលការរៀនសូត្រចេះដឹងហើយ ដល់ធំឡើងរមែងតាំងខ្លួនបានមិនក្រលំបាក, មនុស្សជំងឺ កាលបានទទួលការព្យាបាលរោគសះស្បើយហើយរមែងធ្វើការងារចិញ្ចឹមខ្លួនដោយស្រួលឡើងវិញ។

ការលះទ្រព្យរបស់ខ្លួនទំនុកបម្រុងដល់មនុស្សទាំងឡាយដោយមេត្តាករុណា ឈ្មោះថាជាការលះសុខយ៉ាងតូចដូរយកសុខយ៉ាងធំទូលាយ, ការលះបង់ប្រយោជន៍បំណែកខ្លួន ដើម្បីការពារភ័យអន្តរាយរបស់មនុស្សច្រើន ឬដើម្បីជួយដោះទុក្ខគេ ក៏ចាត់ថាជាការលះសុខយ៉ាងតូច ដោយប៉ងប្រយោជន៍យ៉ាងធំទូលាយដូចគ្នា ។ ព្រះបោរាណាចារ្យពោលរឿងព្រះពោធិសត្វដែលបំពេញទានបារមី តែងលះបុត្រភរិយា អវយវៈក្នុងរាងកាយនិងជីវិតរបស់ព្រះអង្គនោះ ក៏ដើម្បីសម្តែងអធ្យាស្រ័យដ៏ធំទូលាយរបស់ព្រះអង្គ ។

ការបរិច្ចាគដោយការលះ ដូចពោលមកហើយនេះលោកហៅថា ចាគសម្បទា ។

បាគៈ ការលះទ្រព្យជាទានមានអានិសង្សអាចឲ្យសម្រេចប្រយោជន៍ជាច្រើនប្រការ ដូចពោលមកនេះ ព្រោះហេតុនោះបានជាព្រះសក្យមុនីបរមគ្រូ ទ្រង់លើកឡើងសម្តែងជាសម្បទាទី ៣ រងពីសីលសម្បទា ។

៤- បញ្ញាសម្បទា : កុលបុត្រក្នុងលោកនេះជាមនុស្សមានបញ្ញា ដឹងសព្វ បំពោះហេតុជាទីកើត ទីរលត់នៃសង្ខារជាបញ្ញាប្រសើរអាចបាក់ផ្ទះកម្ចាត់បង់កិលេស ដោយមិនសល់ឲ្យដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។

ធម្មជាតិជាគ្រឿងពិចារណាឃើញវិសេស ឃើញច្បាស់បំពោះការកុសល ហៅថា បញ្ញា ។

ក្នុងព្រះសូត្រនេះ ព្រះបរមសាស្តាទ្រង់លើកយកឧទយព្វ-យញ្ញាណឡើងសម្តែងជានិទ្ទេស, មានសេចក្តីថា ធម្មជាតិដែលដឹងច្បាស់នូវសេចក្តីកើត និងសេចក្តីរលត់របស់បញ្ចក្ខន្ធហៅថា បញ្ញា, បញ្ញាបែបនេះ ឈ្មោះថា ឧទយព្វយញ្ញាណ។

អធិប្បាយ : ឧទយព្វយញ្ញាណនោះ គឺបញ្ញាពិចារណាឃើញច្បាស់នូវនិព្វត្តិលក្ខណៈ គឺលក្ខណៈដែលកើតនៃនាមរូប

និងវិបរិណាមលក្ខណៈ គឺ លក្ខណៈ ដែលប្រែប្រួលបែកធ្លាយទៅតែនាមរូប ។ និព្វត្តិលក្ខណៈមាន ៥ យ៉ាង គឺអវិជ្ជា ១ តណ្ហា ១ ឧបាទាន ១ កម្ម ១ អាហារ ១, បំណែកខាងវិបរិណាមលក្ខណៈ ក៏មាន ៥ យ៉ាងដូចគ្នា គឺខន្ធទាំង ៥ នេះ ខន្ធមួយៗមានលក្ខណៈ ១០ គឺការកើតឡើង ៥ ការប្រែក្លាយរលត់រលាយទៅវិញ ៥ រួមខន្ធទាំង ៥ ក៏បានទៅជាលក្ខណៈ ៥០ គត់ ។ ក្នុងរូបក្ខន្ធនោះ យោគីគប្បីពិចារណាចំពោះនិព្វត្តិលក្ខណៈនៃរូបថា រូបនេះតែងកើតព្រោះអវិជ្ជា ដែលជាកិលេសជាតិនាំសត្វឲ្យវង្វេង មិនឲ្យដឹងច្បាស់នូវការពិត ១ រូបកើតព្រោះតណ្ហា ដែលជាកិលេសជាតិនាំសត្វឲ្យញាប់ញ័រអន្ទះសា ១ រូបកើតព្រោះឧបាទាន ដែលជាកិលេសជាតិនាំសត្វឲ្យប្ដូកជាប់នៅក្នុងសង្សារវដ្ដ១ រូបកើតព្រោះកម្មជាកុសលនិងអកុសល ដែលជាផ្លូវនាំសត្វឲ្យអន្ទោលវិលវល់ក្នុងភព ១ រូបកើតព្រោះអាហារ ដែលធ្វើឲ្យរូបកាយចម្រើន ១, បំណែកខាងវិបរិណាមលក្ខណៈនៃរូបនោះ ក៏គួរយោគីពិចារណាថា រូបតែងប្រែប្រួលទៅរលត់ទៅ ក៏ព្រោះអវិជ្ជារលត់ ១

រូបរលត់ទៅក៏ព្រោះតណ្ហារលត់ ១ រូបរលត់ទៅក៏ព្រោះឧបាទានរលត់ ១ រូបរលត់ទៅក៏ព្រោះកម្មរលត់ ១ រូបរលត់ទៅក៏ព្រោះអាហាររលត់ ១ ។

កាលបើយោគីបានពិចារណាចំពោះនិព្វត្តិលក្ខណៈ៥ វិបរិណាមលក្ខណៈ ៥ រួមជា ១០ ក្នុងរូបក្ខន្ធមួយដោយប្រការដូច្នេះហើយ គប្បីពិចារណាខាងនិព្វត្តិលក្ខណៈ ៥ និងវិបរិណាមលក្ខណៈ ៥ របស់វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធតទៅទៀត ដូចគ្នានឹងរូបក្ខន្ធ ផ្សេងគ្នាតែត្រង់អាហារនោះ ឲ្យយកផស្សៈដាក់ជំនួសដូច្នេះគឺវេទនាកើតឡើង ព្រោះការកើតឡើងនៃផស្សៈ, វេទនារលត់ទៅក៏ព្រោះការរលត់ទៅនៃផស្សៈ សញ្ញាកើតឡើងព្រោះការកើតឡើងនៃផស្សៈ សញ្ញារលត់ទៅក៏ព្រោះការរលត់ទៅនៃផស្សៈ សង្ខារកើតឡើង ព្រោះការកើតឡើងនៃផស្សៈ, សង្ខាររលត់ទៅ ក៏ព្រោះការរលត់ទៅនៃផស្សៈ ក្នុងវិញ្ញាណក្ខន្ធ យកអាហាចេញហើយដាក់នាមរូបជំនួសដូច្នេះ គឺវិញ្ញាណកើតឡើងព្រោះការកើតឡើងនៃនាមរូប វិញ្ញាណរលត់ទៅក៏ព្រោះការរលត់ទៅនៃនាមរូប ។

និព្វត្តិលក្ខណៈនិងវិបរិណាមលក្ខណៈរបស់វេទនាសញ្ញា សង្ខារ វិញ្ញាណមានសេចក្តីដូចគ្នានិងប្លែកអំពីលក្ខណៈរបស់រូប ដូចន័យដែលពណ៌នាមកប៉ុណ្ណោះ ។

បញ្ញារបស់យោគីដែលយល់ច្បាស់ក្នុងនិព្វត្តិលក្ខណៈនិងវិបរិណាមលក្ខណៈ គឺទីកើតនិងទីរលត់របស់ខន្ធទាំង ៥ ដូច្នេះ ឈ្មោះថា ឧទយព្វយញ្ញាណ ។

ឧទយព្វយញ្ញាណនេះ ឲ្យយោគីអ្នកបម្រើន ពិចារណាឲ្យឃើញច្បាស់ថា ខន្ធទាំង ៥ ជារបស់មិនទៀងពិត ។

ការបរិបូណ៌ដោយការពិចារណា មានពិចារណាឃើញច្បាស់ក្នុងខន្ធទាំង ៥ ថាជារបស់មិនទៀង ដូចពោលមកនេះជាដើម ហៅថា បញ្ញាសម្បទា ។

បញ្ញានេះ ជាចេតសិកមួយ ក្នុងពួកសោភនចេតសិក ជាធំជាប្រធានលើចេតសិកទាំងពួង សូម្បីក្នុងសម្បទាទាំង ៤ ដែលជាហេតុឲ្យសម្រេចប្រយោជន៍ក្នុងបរលោក នេះ ក៏មានបញ្ញាសម្បទាជាប្រធានដែរ ។ អធិប្បាយថា បុគ្គលនឹងមានសទ្ធាក្តី រក្សាសីលក្តី បរិច្ចាគទានក្តី លុះតែមានបញ្ញាផង ទើប

មានផលច្រើន ព្រោះបញ្ញាទុកជាប្រទីប សម្រាប់បំភ្លឺធម្មជាតិទាំងពួង ។ ហេតុនេះ ទើបព្រះបរមគ្រូទ្រង់លើកឡើងសម្តែងជាខាងចុងបំផុតសម្បទាទាំងពួង ។

ធម៌ ៤ យ៉ាង គឺ សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា បញ្ញាសម្បទា ជាធម៌មានគុណានុភាពអាចញុំាងកុលបុត្រឲ្យសម្រេចប្រយោជន៍ក្នុងបរលោក សមគួរតាមសេចក្តីប្រាថ្នា ។

កុលបុត្រ អ្នកមានបំណងចង់បានសេចក្តីសុខក្នុងលោកខាងមុខ គប្បីញុំាងសម្បទាទាំង ៤ យ៉ាងនេះឲ្យបរិបូណ៌ចុះ ។

ចប់សម្បរាយិកត្ថប្រយោជន៍

# បរមត្ថប្រយោជន៍

## អធិប្បាយប្រយោជន៍ប្រសើរបំផុត

ព្រះនិព្វាន, អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាចាត់ជាបរមត្ថប្រយោជន៍ ព្រោះជាផលយ៉ាងខ្ពស់បំផុត ដែលលោកអ្នកមានវាសនាកសាងខ្ពស់ៗតែងបានសម្រេច រកផលអ្វីៗក្នុងលោកនេះនិងលោកខាងមុខប្រៀបផ្ទឹមគ្មាន, ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់សរសើរថា "ព្រះនិព្វានជាគុណជាតប្រសើរបំផុតពេញប្រៀបដោយបរមសុខ មិនបេះអស់មិនបេះស្ងួត ជាផលបំផុតដែនរបស់បុថុជ្ជន" ព្រោះព្រះនិព្វានជាគុណជាតរំលត់កងកិលេសទាំងមូល ។ ឯឧបាយជាគ្រឿងធ្វើឱ្យដល់នូវព្រះនិព្វាននោះ មាននៅក្នុងពួកបុថុជ្ជនដោយពិតបើលងគិតប្រៀបធៀបល្បងមើល ក្នុងខណៈដែលយើងកើតសេចក្តីត្រេកត្រអាលសេចក្តីស្រឡាញ់ សេចក្តីក្រោធខឹង សេចក្តីវង្វេងជរាបដល់ងងឹតស្លុបមិនដឹងការខុសត្រូវ និងក្នុងខណៈដែលយើងស្វាងបាកកិលេសនោះៗម្តងម្កាល តាមនិស្ស័យនៃយើងជាបុថុជ្ជន, ផលដែលយើងត្រូវបានទទួលក្នុង ២ ខណៈនោះតើផ្សេងគ្នាយ៉ាង

ណាខ្លះ? ផលខាងណាប្រព្រឹត្តទៅដើម្បីទុក្ខ, ផលខាងណាប្រព្រឹត្តទៅដើម្បីសន្តិសុខ? សេចក្ដីរលត់កងកិលេសទាំងមូលបានដាច់ខាតអ្នកប្រាជ្ញលោកហៅថា "ព្រះនិព្វាន", ឯព្រះនិព្វាននោះនឹងជាបរមសុខមែនឬទេ? រឿងនេះបើគិតតាមន័យដូចពោលហើយគង់ដឹងបានដោយខ្លួនឯងថា សូម្បីតែរម្ងាប់តម្រេកឬកំហឹងជាដើមដែលកើតឡើងក្នុងចិត្ត ឲ្យស្ងប់បានតែត្រឹមមួយស្របក់ប៉ុណ្ណោះក៏ស្រួលចិត្តជាងពេលដែលកំពុងមានតម្រេកកំពុងមានកំហឹងនោះណាស់ទៅហើយ បំណាច់បើព្រះនិព្វានដែលជាធម្មជាតរំលត់កិលេសអម្បាលនោះ បានដោយដាច់ខាតនោះតើនឹងជាបរមសុខយ៉ាងណាទៅ? បរមសុខនោះយើងជាបុថុជ្ជនមិនអាចដឹងច្បាស់បាន, ហេតុដូច្នោះ ទើបព្រះនិព្វានបាននាមថាជា បរមត្ថប្រយោជន៍ (ប្រយោជន៍យ៉ាងឆ្ពើមបំផុត) របស់អ្នកដែលបាន ប្រសើរជាងប្រយោជន៍ទាំងពួងជាប្រយោជន៍គួរប្រាថ្នាណាស់របស់ពុទ្ធបរិស័ទក្នុងព្រះពុទ្ធសាសនា,

មានរឿងដំណាលថា៖ កាលដែលព្រះបរមសាស្ដាទ្រង់ដាក់អាយុសង្ខារថា "អំណើះទៅមុខនៅ ៤ ខែទៀត តថាគតនឹង

រលត់ខន្ធបរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែពិសាខ” ។ គ្រានោះភិក្ខុទាំងឡាយដែលជាសេខបុគ្គលក៏នាំគ្នាស្លុតបិត្តមិនបានលះទីគាល់ប្រជុំប្រឹក្សាគ្នាជាពួកៗ, មានតែព្រះធម្មារាមត្ថេរមួយរូបមិនចូលទៅប្រជុំប្រឹក្សាក្នុងពួកភិក្ខុនោះៗឡើយ, លោកត្រិះរិះថា “អាត្មាអញនឹងបំពេញព្យាយាមឲ្យបានសម្រេចអរហត្តក្នុងវេលាព្រះបរមសាស្ដាគង់ព្រះជន្មនៅ”, លុះត្រិះរិះដូច្នេះហើយក៏ចៀសចេញទៅបំពេញសមណធម៌តែម្នាក់ឯង ។ ភិក្ខុទាំង-ឡាយស្ដីឲ្យលោកថា មិនស្រឡាញ់ព្រះបរមសាស្ដា,ក៏នាំយកសេចក្ដីនុ៎ះទៅក្រាបបង្គំទូលព្រះអង្គ, ព្រះអង្គឲ្យហៅព្រះថេរៈនោះមកត្រាស់សួរ, លោកក៏ក្រាបបង្គំទូលតាមគំនិតរបស់លោក ។ ទើបព្រះអង្គប្រទានសព្ទសាធុការឲ្យភិក្ខុទាំងឡាយកាន់យកទុកជាបែបហើយទ្រង់សរសើរ ធម្មានុធម្មប្បដិបត្តិថា៖

**ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ**
**ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ។**

ភិក្ខុអ្នកមានធម៌ជាទីរីករាយ អ្នកត្រេកអរក្នុងធម៌ បាន

ពិចារណាធម៌រឿយ ៗ រំលឹកធម៌រឿយ ៗ រមែងមិនសាបសូន្យ បាកព្រះសទ្ធម្មឡើយ ។

វេលាចប់ព្រះសទ្ធម្មទេសនា, ព្រះថេរៈនោះ បានសម្រេច អរហត្តផល ដែលជាផលប្រយោជន៍យ៉ាងខ្ពើមបំផុតក្នុង ព្រះពុទ្ធសាសនា ។

នាំរឿងនេះមក, ដើម្បីឱ្យឃើញច្បាស់ថា ព្រះនិព្វានជា ផលប្រយោជន៍យ៉ាងឧត្តមបំផុត ជាទីប្រាថ្នាក្រៃពេករបស់ សប្បុរសទាំងឡាយដែលជាពុទ្ធសាសនិកជន ។

អ្នកមានបំណងចង់បានបរមត្ថប្រយោជន៍ ត្រូវមានធម៌ ជាទីរីករាយ ត្រូវត្រេកអរក្នុងធម៌ ត្រូវពិចារណាធម៌រឿយៗ ត្រូវរំលឹកធម៌រឿយៗកុំបោះបង់ព្រះសទ្ធម្ម ។

ធម៌ដែលគួររីករាយ គួរត្រេកអរ គួរពិចារណា គួររំលឹក រឿយៗដើម្បីញុំាងបរមត្ថប្រយោជន៍ឱ្យសម្រេចនោះមានច្រើន ប្រការ, តែក្នុងទីនេះ សូមស្រង់យកធម៌ ១០ ប្រការដែលមាន នាមប្រាកដថា បារមីធម៌ប្រែថា ធម៌ញុំាងជនឱ្យដល់ត្រើយ គឺ ព្រះនិព្វាន ដែលជាបរមត្ថប្រយោជន៍ឱ្យសម្រេច មកសម្ដែង ។

បារមីធម៌ ១០ នោះ គឺ

១- **ទាន** ការឱ្យ

២- **សីល** ការសង្រួមកាយវាចាឱ្យវាបសារ

៣- **នេក្ខម្ម** ការចេញបាកកាម

៤- **បញ្ញា** ការដឹងច្បាស់តាមពិត

៥- **វិរិយ** ការព្យាយាម

៦- **ខន្តី** ការអត់ធន់

៧- **សច្ច** ការប្រព្រឹត្តទៀងត្រង់

៨- **អធិដ្ឋាន** ការតាំងចិត្តខ្ជាប់ខ្ជួន

៩- **មេត្តា** ការផ្សាយមេត្រីទូទៅ

១០- **ឧបេក្ខា** ការតាំងចិត្តជាកណ្តាលក្នុងអារម្មណ៍ទាំងពួង

បារមីធម៌ទាំង ១០ ប្រការនេះ ជានិស្ស័យដ៏សំខាន់របស់ព្រះពោធិសត្វដែលប្រាថ្នាជាព្រះពុទ្ធ និងសាធុជនដែលប្រាថ្នាជាពុទ្ធសាវ័ក លោកធ្លាប់ធ្វើ ធ្លាប់សាង ដើម្បីឱ្យបានសម្រេចព្រះនិព្វានដែលជាបរមត្ថប្រយោជន៍ ។

កុលបុត្រដែលមានបំណងចង់បានបរមត្ថប្រយោជន៍ គឺព្រះនិព្វាន ត្រូវបម្លងយកនិស្ស័យរបស់ព្រះពុទ្ធ និងពុទ្ធសាវ័កមកដាក់ជានិស្ស័យរបស់ខ្លួនរៀងខ្លួន គឺព្រះពុទ្ធ និងពុទ្ធសាវ័កលោកធ្លាប់សាងបារមីធម៌ទាំង ១០ ប្រការនោះដូចម្ដេចខ្លះ, យើងត្រូវធ្វើតាមបែបលោកទាំងនោះ ឲ្យដូចលោក កុំឲ្យជ្រៀលិសពីលោក ទើបសម្រេចដូចលោកបាន ។

ពុទ្ធសាសនិកជន គប្បីពិចារណាត្រួតត្រាមើលនិស្ស័យរបស់ខ្លួន ឲ្យឃើញពិតតាមភាពរបស់ខ្លួនថា “បារមីធម៌ទាំង ១០ មានទានជាដើម មានឧបេក្ខាជាទីបំផុតនោះ មានក្នុងខ្លួនអាត្មាអញហើយឬនៅ? ”បើប្រសិនជាមិនទាន់មាន គួរធ្វើឲ្យមានឡើង បើមានហើយតែមិនទាន់គ្រប់គ្រាន់ មិនទាន់ពេញលេញ, ត្រូវបំពេញ ឲ្យពេញលេញ ឲ្យគ្រប់គ្រាន់ឡើង ដើម្បីឲ្យបានសម្រេចបរមត្ថប្រយោជន៍ គឺព្រះនិព្វានដែលជាទីប្រាថ្នា ជាទីពេញចិត្ត របស់ពុទ្ធបរិស័ទ ទូទៅក្នុងពុទ្ធសាសនាក្នុងកាលជាអនាគត ។

ចប់បរមត្ថប្រយោជន៍

## និគមវចនៈ

ពុទ្ធភាសិតដែលសម្តែងអំពីប្រយោជន៍ ៣ យ៉ាង គឺ

**១- ទិដ្ឋធម្មិកត្ថៈ** ប្រយោជន៍បច្ចុប្បន្ន

**២- សម្បរាយិកត្ថៈ** ប្រយោជន៍បរលោក

**៣- បរមត្ថៈ** ប្រយោជន៍ព្រះនិព្វាន

នេះ ជាភាសិត ជម្រាលពីរាក់ទៅជ្រៅ ពីទាបទៅខ្ពស់ ។

តាមទំនងនេះ, ឃើញថា ពុទ្ធសាសនា ប្រដៅពុទ្ធបរិស័ទ ឲ្យស្វែងរកប្រយោជន៍បច្ចុប្បន្នជាទី ១ ប្រយោជន៍បរលោកជាទី ២ ប្រយោជន៍ព្រះនិព្វានជាទី ៣ ។

ពុទ្ធបរិស័ទត្រូវប្រតិបត្តិឲ្យគ្រប់ទាំង៣តាមលំដាប់លំដោយ កុំប្រាសពីចុងមកដើម គឺត្រូវប្រតិបត្តិស្វែងរកតាំងពីប្រយោជន៍បច្ចុប្បន្នជាដើមហូរហែទៅ កុំលះបោលប្រយោជន៍បច្ចុប្បន្ន ទើបត្រូវតាមអធ្យាស្រ័យរបស់ពុទ្ធសាសនា ដែលមានជម្រាលពីរាក់ទៅជ្រៅ ដូចមហាសមុទ្រ, គឺថាមុនដំបូងត្រូវស្វែងរករៀនវិជ្ជា មានវិជ្ជាអក្សរ និងវិជ្ជាខាងផ្លូវរកស៊ីជាដើម លុះបេះវិជ្ជាទាំងនោះសព្វគ្រប់ហើយ ត្រូវខំរកទ្រព្យសម្បត្តិជាប្រយោជន៍ឃើញ

ទាន់ភ្នែក លុះបានទ្រព្យសម្បត្តិហើយ ត្រូវបំណាយធ្វើបុណ្យទានជាប្រយោជន៍ទៅខាងមុខ សមគួរតាមកម្លាំងទ្រព្យ និងបំពេញបារមី ជាប្រយោជន៍ព្រះនិព្វានតៗទៅ ។ បើមិនមានបំណោះ មិនងាយនឹងរកទ្រព្យ, បើមិនមានទ្រព្យមិនងាយនឹងធ្វើបុណ្យទាន, បើមិនធ្វើបុណ្យទាន និស្ស័យនៃព្រះនិព្វានក៏នៅឆ្ងាយដាច់ស្រយាលណាស់ មិនងាយនឹងចូលទៅជិតបានឡើយ ។

ពុទ្ធសាសនាមានប្រដៅផ្លូវលោកដោយពិស្តារ ដែលស្រង់យកមករៀបរៀងខាងដើមនោះ សង្ខេបនៅឡើយ ។ កុំយល់ថា ពុទ្ធសាសនាមិនប្រដៅផ្លូវលោក ត្រូវយល់ថាពុទ្ធសាសនាមានប្រដៅផ្លូវលោកច្រើនជាអនេកណាស់ដែរគឺប្រដៅពុទ្ធបរិស័ទឲ្យខំរៀនសិល្បសាស្ត្រ ឲ្យខំរកទ្រព្យសម្បត្តិឲ្យមានបាន មិនប្រដៅឲ្យល្ងង់ ឲ្យខ្សត់ខ្សោយទេ ប៉ុន្តែប្រដៅឲ្យខំរកដោយសម្មាអាជីវៈត្រឹមត្រូវតាមគន្លងធម៌ ជាអំពើដ៏សុភាព និងប្រដៅមិនឲ្យជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិនោះពេក គឺប្រដៅឲ្យបរិច្ចាគទ្រព្យក្នុងទីដែលគួរបរិច្ចាគ សមគួរតាមកម្លាំង

មិនឲ្យកំណាញ់ស្វិតខុសទំនង ព្រោះសេចក្ដីកំណាញ់ជាស្នឹម ជាប្រែះឲ្យទោសយ៉ាងខ្លាំង អាចទម្លាក់អ្នកកំណាញ់ឲ្យធ្លាក់ទៅអបាយ ។

ព្រោះហេតុនេះ ពុទ្ធមាមកជនត្រូវខំរកប្រយោជន៍បច្ចុប្បន្នឲ្យណាស់ កុំបណ្ដែតបណ្ដោយ ដើម្បីញ៉ាំងប្រទេសជាតិឲ្យបម្រើនដុះដាលល្វតលាស់ឡើង ហើយខំរកប្រយោជន៍បរលោកនិងព្រះនិព្វាន សមគួរតាមកម្លាំងដែលអាចធ្វើបានតទៅ ។

ចប់ប្រយោជន៍ ៣ យ៉ាង